ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣
# ស្ដីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

សហការ

បង្ការ

បង្ក្រាប

ផ្ដន្ទាទោស

សង្គ្រោះ

ការពារ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គ.ជ.ប.ជ

NATIONAL COMMITTEE FOR COUNTER TRAFFICKING (N.C.C.T)

របាយការណ៍នេះអាចទាញយកពី គេហទំព័រ

**www.ncct.gov.kh**

ឯកសារផែនការយុទ្ធសាស្ត្រជាតិនេះ ត្រូវបានបោះពុម្ពជាពីរភាសា ចំនួន១០០០ច្បាប់ ដោយ ថវិកាជាតិ នៅរោងពុម្ពអន្តរជាតិ
និងចូលរួមដោយ

# សារលិខិត

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៩

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន**

ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ នេះ គឺជាផែនទីបង្ហាញផ្លូវថ្មីមួយ ដែលអនុលោមតាមស្ថានភាព និងសភាពការណ៍បទល្មើស ដែលបានរកឃើញក្នុងតំណាក់កាល៥ឆ្នាំកន្លងមក ក៏ដូចជាការប្រមើលមើលទៅលើលទ្ធភាពក្នុងការដោះស្រាយភាពប្រឈមក្នុងរយៈពេលប្រាំឆ្នាំទៅមុខ ។ មិនតែប៉ុណ្ណោះ ផែនការយុទ្ធសាស្ត្រនេះ ក៏ជាមូលដ្ឋានក្នុងការរៀបចំសកម្មភាពនៅតាម ក្រសួង ស្ថាប័ន អង្គភាពនីមួយៗតាមបណ្តាឆ្នាំ ដែលឆ្លើយតបទៅនឹងទស្សនៈវិស័យ និងគោលដៅរួមរបស់ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ.ជ.ប.ជ)។

លទ្ធផលសកម្មភាពដែល ក្រសួង ស្ថាប័ន អង្គភាពជំនាញ ក៏ដូចជាអង្គការដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលធ្វើឱ្យសម្រេចកន្លងមក បានបញ្ជាក់អំពីការប្តេជ្ញាចិត្តក្នុងការរួមចំណែកដល់ការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងបានបន្តពង្រឹងការអនុវត្តច្បាប់ ក៏ដូចជាការជួយផ្តល់កិច្ចការពារដល់ជនរងគ្រោះ គ្រប់ភេទគ្រប់វ័យផងដែរ ។

បន្តទៅនេះ សកម្មភាពទាំងឡាយគប្បីចាប់ផ្តើមពីការកែលម្អចំណុចខ្វះខាត និងពង្រឹងតួនាទីរបស់ស្ថាប័នក្នុងការអនុវត្តភារកិច្ច តាមដាន វាយតម្លៃ និងគ្រប់គ្រងឱ្យបានល្អប្រសើរ រៀបចំផែនការសកម្មភាពលម្អិតតាមស្ថាប័ន និងជំរុញអនុវត្តឱ្យខាងតែបាន ដើម្បីបង្កើនភាពជឿជាក់ និងភាពកក់ក្តៅរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសុវត្ថិភាព ។

ក្នុងនាម**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ខ្ញុំសូមលើកទឹកចិត្ត គាំទ្រ ជួយសម្របសម្រួលរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់គ្រប់អង្គភាព ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីរក្សាការពារភាពសុខដុមរមនារបស់ប្រជាពលរដ្ឋយើង ។

សូមជោគជ័យ សិរីមង្គលគ្រប់ប្រការមានដល់លោក អ្នកគ្រប់គ្នាកុំបីខាន។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**ហត្ថលេខា**

**ស ខេង**

# មាតិកា


**ពាក្យសរសេរកោត** ........ iii

**ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣ ស្តីពីការ ប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស** ........ ១

**ក.** **ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិ** ........ ១

**ខ.** **មូលដ្ឋានបង្អែកនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩ - ២០២៣** ........ ៣

ខ.១. លិខិតូបករណ៍ជាតិ និងអន្តរជាតិ ........ ៣

ខ.១.១. លិខិតូបករណ៍ជាតិ មានជាអាទិ៍ ........ ៣

ខ.១.២. លិខិតូបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ ........ ៣

ខ.២. យន្តការជាតិ និងអន្តរជាតិ ........ ៤

ខ.២.១. យន្តការជាតិ មានជាអាទិ៍ ........ ៤

ខ.២.២. យន្តការតំបន់ និងអន្តរជាតិ ........ ៦

ខ.៣. ឯកសារគោលនៃផែនការសកម្មភាពជាតិ ឆ្នាំ ២០១៧-២០១៨ ........ ៧

ខ.៤. បច្ចុប្បន្នភាពនៃស្ថានភាព ឆ្នាំ២០១៧ និង២០១៨ ........ ៨

១. បញ្ហាប្រឈម និងដំណោះស្រាយសម្រាប់ពលករនៅប្រទេសគោលដៅ ........ ៨

២. បញ្ហាពលករដែលត្រូវបានបញ្ជូនត្រឡប់ ឬវិលត្រឡប់ ........ ៩

៣. តម្រូវការដោះស្រាយបញ្ហាកុមារ ក្នុងសហគមន៍ ........ ១១

៤. ការគ្រប់គ្រងកម្លាំងពលកម្ម ដែលមានសក្តានុពលសម្រាប់ការធ្វើទេសន្តរប្រវេសន៍
និងកម្លាំងសម្រាប់បំពេញឱ្យ តម្រូវការការងារក្នុងស្រុក ........ ១២

៥. ពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ និងអំពើពាក់ព័ន្ធ ........ ១២

ខ.៥. ទិសដៅសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ ........ ១៣

ខ.៦. គម្រោងសកម្មភាពក្រសួងស្ថាប័ន ........ ១៣

ខ.៧. មេរៀន បទពិសោធន៍ និងការអនុវត្តល្អៗ ........ ១៤

**គ. ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្ដីពីការ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស** ...... ១៦
គ.១. ទស្សនៈវិស័យ ...... ១៦
គ.២. បេសកកម្ម ...... ១៦
គ.៣. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងអំពើជួញដូរមនុស្ស (ឆ្នាំ២០១៩-២០២៣) ...... ១៦
គ.៤. គុណតម្លៃស្នូលនៃផែនការសកម្មភាពជាតិ ...... ១៧
គ.៥. គោលដៅ និងគោលបំណង ...... ២០
គ.៦. យុទ្ធសាស្ត្រ ...... ២០
យុទ្ធសាស្ត្រទី១ ៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ...... ២១
យុទ្ធសាស្ត្រទី២ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ ...... ២១
យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ...... ២២
យុទ្ធសាស្ត្រទី៤ ៖ បង្កើនកិច្ចការពារជនរងគ្រោះ (ជាពិសេស ស្ត្រី និងកុមារ) ...... ២២
**ឃ. ការត្រួតពិនិត្យ និងវាយតម្លៃ** ...... ២៣
**តារាងសកម្មភាព តាមយុទ្ធសាស្ត្រ** ...... ២៤
**ឧបសម្ព័ន្ធ** ...... ៧៦

# ពាក្យសរសេរកាត់

| | |
|---|---|
| CARE | អង្គការឃែរ |
| CHC | បណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ជាតិ |
| COMMIT | គំនិតផ្ដួចផ្ដើមថ្នាក់រដ្ឋមន្ត្រីក្នុងតំបន់ទន្លេមេគង្គដែលមានការសម្របសម្រួលប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| CTIP | ការប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoFAIC | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| MoVSY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoT | ក្រសួងទេសចរណ៍ |
| MoWA | ក្រសួងកិច្ចការនារី |
| NCS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិ(មុន ខែមិថុនា ឆ្នាំ២០១៤) |
| NC-STSLS | គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ |
| NPA | ផែនការសកម្មភាពជាតិ |
| P/MC | គណៈកម្មាធិការខេត្ត/រាជធានី |
| P/MCS | លេខាធិការដ្ឋានគណៈកម្មាធិការខេត្ត/រាជធានី |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SAF/UNW-ILO | កម្មវិធីសុវត្ថិភាពនិងយុត្តិធម៌របស់អង្គការ UNWOMEN និង ILO |
| STSLS | ការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ |

| | |
|---|---|
| UNACT | សកម្មភាពអង្គការសហប្រជាជាតិដើម្បីសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស |
| UN WOMEN | ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNODC | ការិយាល័យប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ |
| USAID | ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក |

# ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣
# ស្តីពីការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## ក.ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិ

«ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៩-២០២៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» គឺជាផែនទីបង្ហាញផ្លូវលើកទី៣ ដែលរៀបចំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺ៖

លើកទី១គឺ «ផែនការសកម្មភាព សម្រាប់ឆ្នាំ២០១១-២០១៣»

លើកទី២គឺ «ផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០១៤-២០១៨» ។

លើកទី៣ គឺ «ឯកសារផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣» នេះ ។




កិច្ចប្រជុំពិភាក្សាថ្នាក់ជាតិត្រូវបានធ្វើឡើង បន្ទាប់ពីផែនការសកម្មភាពជាតិឆ្នាំ២០១៤-២០១៨ ត្រូវបានបញ្ចប់ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំបន្ត (២០១៩-២០២៣) ដោយមានការចូលរួមពីគ្រប់សមាសភាពក្នុងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ ។ ការវាយតម្លៃពាក់កណ្តាលអណត្តិនៃផែនការជាតិ ក្នុងឆ្នាំ២០១៦[1] អំពីប្រសិទ្ធភាព ផលប៉ះពាល់ ភាពប្រឈម និងចំណុចខ្វះខាតផ្សេងៗ បានផ្តល់ជាធាតុចូលសម្រាប់ការកសាង «ឯកសារផែនការគោល» មួយ ដើម្បីជួយតម្រង់ទិសកែលម្អការអនុវត្តនៅឆ្នាំបន្តទៀត ។

[1] ធ្វើឡើងដោយអ្នកជំនាញវាយតម្លៃ គាំទ្រដោយអង្គការវិនរ៉ក់អន្តរជាតិ (Winrock International) ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID)

ឯកសារផែនការគោលនេះ ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានបង្អែកសម្រាប់ការកសាងផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) គួបផ្សំជាមួយការពិគ្រោះយោបល់បន្ថែមជាបន្តបន្ទាប់ជាមួយក្រសួង ស្ថាប័ន រាជធានី ខេត្ត និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ។














ទីបំផុត «ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៩-២០២៣» នេះ ត្រូវបានប្រកាសឱ្យអនុវត្តជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅខែតុលា ឆ្នាំ២០១៩ ដោយមានថ្នាក់ដឹកនាំក្រសួងស្ថាប័នជាសមាជិក មន្ត្រីជំនាញ អង្គការដៃគូជាតិ និងអន្តរជាតិ និងគណៈកម្មាធិការរាជធានី-ខេត្ត ចូលរួមយ៉ាងច្រើនកុះករ ដើម្បីបានជ្រាប និងទទួលអនុវត្ត ។

## ខ. មូលដ្ឋានបង្អែកនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩ - ២០២៣

### ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺផ្អែកលើ៖

១. លិខិតូបករណ៍ជាតិ និងអន្តរជាតិ
២. យន្តការជាតិ និងអន្តរជាតិ
៣. ឯកសារគោលនៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ ឆ្នាំ២០១៧-២០១៨ ដែលបានប្រកាសផ្សព្វផ្សាយ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ ដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ
៤. ស្ថានភាពជាក់ស្តែង និងការប៉ាន់ប្រមាណអំពីបម្រែបម្រួលនៃស្ថានភាពទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស ប្រៀបធៀបនឹងលទ្ធផលនៃការអនុវត្តផែនការ ២០១៤-២០១៨
៥. ទិសដៅសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
៦. និងរួមបញ្ចូលសកម្មភាពទាំងឡាយរបស់ក្រសួងស្ថាប័នជាសមាជិក ដែលគ្រោងឡើងសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់
៧. មេរៀន បទពិសោធន៍ និងការអនុវត្តល្អៗតាមរយៈការធ្វើបច្ចុប្បន្នភាព និងកែលម្អនៃផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមក
៨. គោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា
៩. ជាតុចូលពីអង្គការដៃគូអនុវត្ត ជាតិ និងអន្តរជាតិ ។

### ខ.១. លិខិតូបករណ៍ជាតិ និងអន្តរជាតិ

**ខ.១.១. លិខិតូបករណ៍ជាតិ** មានជាអាទិ៍៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
- ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ
- គោលនយោបាយទេសន្តរប្រវេសន៍កម្ពុជា
- គោលនយោបាយភូមិឃុំមានសុវត្ថិភាព
- គោលនយោបាយជាតិចតុកោណ តំណាក់កាលទី៤ មុំទី៤ ។

**ខ.១.២. លិខិតូបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ៖**

១. លិខិតូបករណ៍អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិ អន្តរជាតិ និងតំបន់ ពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិជនទេសន្តរប្រវេសន៍ការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន អំពើជួញដូរមនុស្ស ការគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ល។

២. អនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសក្នុងតំបន់ និងជាអន្តរជាតិ ។

---
មានរៀបរាប់ក្នុងឧបសម្ព័ន្ធ(១)
មានរៀបរាប់ក្នុងឧបសម្ព័ន្ធ(១)

## ១.២. យន្តការជាតិ និងអន្តរជាតិ

### ១.២.១. យន្តការជាតិ មានជាអាទិ៍៖

យន្តការជាតិឈ្មោះថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ ដែលបង្កើតឡើងដោយ ព្រះរាជក្រឹត្យ លេខនស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ នៅតែមានតួនាទីសំខាន់ក្នុងការប្រមូលផ្តុំកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប សម្រាប់ការឆ្លើយតបទៅនឹងបទល្មើសជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ។

> «គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាយន្តការជាតិដែលមានភារកិច្ចដឹកនាំ សម្របសម្រួល ជំរុញ ប្រមូលព័ត៌មាន ចងក្រងទិន្នន័យ និងផ្តួចផ្តើមកសាងច្បាប់ គោលនយោបាយ ផែនការនានា និងជំរុញអនុវត្តដោយមានការចូលរួមពីបណ្តាក្រសួង ស្ថាប័នជាសមាជិក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ (NGOs) ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដោយរួមសហការគ្នារិះរកវិធានការឆ្លើយតបតាមរយៈសកម្មភាពបង្ការទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ប្រជាជនកម្ពុជា និងមនុស្សទាំងឡាយពីភាពរងគ្រោះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលុបបំបាត់អំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាអាទិ៍មានការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរកុមារ ទារក ការជួញដូរសរីរាង្គ ...។ល។ »

យន្តការនេះ ដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន មានក្រសួងចំនួន ២១ និងអង្គភាពជំនាញចំនួនប្រាំ ជាសមាជិក ។**

- ក្រសួង ជាសមាជិកទាំង២១ គឺ៖

  (១)ក្រសួងមហាផ្ទៃ (២)ក្រសួងអប់រំ យុវជននិងកីឡា (៣)ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា (៤)ក្រសួងយុត្តិធម៌ (៥)ក្រសួងកិច្ចការនារី (៦)ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ (៧)ក្រសួងសុខាភិបាល (៨)ក្រសួងទេសចរណ៍ (៩)ទីស្តីការគណៈរដ្ឋមន្ត្រី (១០)ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (១១)ក្រសួងការពារជាតិ (១២)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៣)ក្រសួងផែនការ (១៤)ក្រសួងព័ត៌មាន (១៥)ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (១៦) ក្រសួងអភិវឌ្ឍន៍ជនបទ (១៧)ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (១៨)ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ (១៩)ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (២០)ក្រសួងធម្មការ និងសាសនា (២១)ក្រសួងមុខងារសាធារណៈ ។

- **អង្គភាពជំនាញចំនួន៥ ជាសមាជិក គឺ៖**
(១)អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ (២)កងរាជអាវុធហត្ថលើផ្ទៃប្រទេស (៣)អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ (៤)អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ (៥)នាយកដ្ឋានកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរៈភូមិន្ទ ។

- **គ.ជ.ប.ជ បែកចេញជា០៦ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន** តែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ គឺ៖
  (១) ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា
  (២) ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  (៣) ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយ អគ្គស្នងការនគរបាលជាតិ
  (៤) ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
  (៥) ក្រុមការងារទំនាក់ទំនងអន្តរជាតិ ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
  (៦) ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

- **គ.ជ.ប.ជ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ** បង្កើតដោយអនុក្រឹត្យលេខ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ជារដ្ឋលេខាធិការមួយរូបមកពីក្រសួងមហាផ្ទៃ ។ អគ្គលេខាធិការដ្ឋាន មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ ជំរុញកិច្ចសហប្រតិបត្តិការរវាងអន្តរក្រសួង ស្ថាប័ន រួមទាំងដៃគូទាំងឡាយក្នុង និងក្រៅប្រទេស ដែលធ្វើការងារពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ផ្តោតការយកចិត្តទុកដាក់លើការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអនុវត្តច្បាប់ រួមមានការស៊ើបអង្កេត បង្ក្រាបបទល្មើស និងជនល្មើស ដែលធ្វើសកម្មភាពជួញដូរមនុស្ស ដើម្បីបញ្ជូនទៅតុលាការធ្វើការផ្តន្ទាទោស សង្គ្រោះ និងផ្តល់កិច្ចការពារដល់ជនរងគ្រោះ ទាំងស្ត្រី បុរស កុមារ ឱ្យមានប្រសិទ្ធិភាពខ្ពស់ក្នុងគោលដៅកាត់បន្ថយ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស លើកកម្ពស់សិទ្ធិ និងគុណភាពជីវិតប្រជាពលរដ្ឋ ។

- **គ.ជ.ប.ជ មានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិ** ដែលនៅតាមបណ្តារាជធានី-ខេត្ត ក៏មានតែងតាំងជាគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ/គ.រ.ប.ជ) តាមសេចក្តីសម្រេចលេខ ០០១/១៤ សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ។ គណៈកម្មាធិការនេះដឹកនាំដោយអភិបាលរាជធានី អភិបាលខេត្ត មានសមាជិកជាប្រធានគ្រប់មន្ទីរ ស្ថាប័នក្រោមឱវាទ និងអភិបាលគ្រប់ ក្រុង ស្រុក ខណ្ឌក្រោមចំណុះ ។ គ.ខ.ប.ជ/គ.រ.ប.ជ មានលេខាធិការដ្ឋាន ដឹកនាំដោយអភិបាលរងមួយរូប និងក្រុមការងារអន្តរមន្ទីរ ស្ថាប័ន ចំនួន៦ ដូចគ្នានឹងថ្នាក់ជាតិដែរ ។ លើសពីនេះទៅទៀត បណ្តាញការងារគណៈកម្មាធិការ មាននៅតាមបណ្តាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ថែមទៀត ។

- ក្រសួង ស្ថាប័ន អង្គភាព ជាសមាជិក គ.ជ.ប.ជ នៅថ្នាក់ជាតិ ក៏ដូចជាមន្ទីរអង្គភាព ជាសមាជិក គ.រ.ប.ជ និងគ.ខ.ប.ជ ក្នុងការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅតាមយុទ្ធសាស្ត្រដែលបានកំណត់ ។
- គ.ជ.ប.ជ មានភារកិច្ចប្រមូលផ្តុំកិច្ចសហការ និងបញ្ញាញាណ ជាមួយគ្រប់ដៃគូពាក់ព័ន្ធ ជាអង្គការអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជនទាំងឡាយ ដើម្បីជាកម្លាំងសរុប ធនធានសរុប មធ្យោបាយសរុប បំពេញចន្លោះខ្វះខាតទាំងឡាយ និងធ្វើឱ្យសម្រេចយុទ្ធសាស្ត្រ ប្រឆាំងការជួញដូរមនុស្ស ។

**ខ.២.២. យន្តការតំបន់ និងអន្តរជាតិ ៖**

- សម្រាប់កិច្ចសហប្រតិបត្តិការជាមួយតំបន់ អាស៊ី ប៉ាស៊ីហ្វិក៖

Bali Process ជាយន្តការតំបន់អាស៊ី ប៉ាស៊ីហ្វិក ដែលចាប់ផ្តើមតាំងពីឆ្នាំ២០០២ ស្តីពី ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងបទឧក្រិដ្ឋពាក់ព័ន្ធដទៃទៀត ។ ការជួបប្រជុំជាប្រចាំថ្នាក់បច្ចេកទេស និងថ្នាក់រដ្ឋមន្ត្រី ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងគំនិតផ្តួចផ្តើមថ្មី អំពីគោលនយោបាយ និងកិច្ចប្រតិបត្តិការនានាដែលជួយដល់ក្នុងការឆ្លើយតប នឹងបញ្ហាឧក្រិដ្ឋកម្មឆ្លងដែននានា ។ យុទ្ធសាស្ត្រ Bali Process សម្រាប់កិច្ចសហប្រតិបត្តិការ គឺរួមទាំងកម្មវិធីសកម្មភាពឆ្ពោះទៅមុខ ការណែនាំការងារក្នុងការអនុវត្តជាអាទិភាពដែលដាក់ទិសដោយ ថ្នាក់រដ្ឋមន្ត្រី[4] ។

ក្រុមការងារ SOMTC សម្រាប់កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន (មាន១០ប្រទេស ហ្វីលីពីន សាំងហ្គាពួរ ឥណ្ឌូណេស៊ី ម៉ាលេស៊ី ប្រ៊ុយណេ ថៃ ឡាវ វៀតណាម កម្ពុជា ភូមា ។

- COMMIT Taskforce កម្ពុជា ជាក្រុមការងារសម្រាប់កិច្ចសហការជាមួយមហាអនុតំបន់មេគង្គ (០៦ប្រទេសមាន ចិន ភូមា ឡាវ ថៃ វៀតណាម កម្ពុជា) ដែលចាប់ផ្តើមពីឆ្នាំ២០០៥ បន្ទាប់ពីកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី១ បានសម្រេចរួមគ្នាក្នុងការរួមសហការគ្នាក្នុងអនុតំបន់ មេគង្គប្រឆាំងការជួញដូរមនុស្សក្នុងឆ្នាំ២០០៤ នាទីក្រុងយ៉ាងហ្គូនប្រទេសមីយ៉ាន់ម៉ា ។

[4] អ្នកដឹកនាំ Bali Process មានឥណ្ឌូណេស៊ី និង អូស្ត្រាលី និងមានសមាជិក ៤៨ រួមទាំង UNHCR (the United Nations High Commissioner for Refugees) IOM (the International Organization for Migration) nig UNODC (the United Nations Office of Drugs and Crime) ព្រមទាំងប្រទេស និងអង្គការអន្តរជាតិមួយចំនួនទៀត ជាអ្នកសង្កេតការណ៍ និងមាន ក្រុមការងារចំពោះកិច្ចផងដែរ ។ ការិយាល័យគាំទ្រថ្នាក់តំបន់ (RSO) សម្រាប់ គាំទ្រដល់ដំណើរការបាលី ។ សន្និសីទលើកទី៦ថ្នាក់រដ្ឋមន្ត្រីបានបញ្ជាក់អំពីគោលបំណងសំខាន់និងអាទិភាពនៃណើរការបាលី តាមរយៈការប្រកាសសេចក្តីថ្លែងការណ៍របស់ដំណើរការបាលីស្តីពីអំពើរត់ពន្ធមនុស្ស អំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មពាក់ព័ន្ធដទៃទៀត។

## ខ.៣. ឯកសារគោលនៃផែនការសកម្មភាពជាតិ ឆ្នាំ ២០១៧-២០១៨




ក្នុងឯកសារគោល បានបញ្ជាក់អំពីតួនាទីភារកិច្ចរបស់ក្រសួង ស្ថាប័នដែលជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានចែងយ៉ាងច្បាស់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចនានា ស្តីពីការបង្កើតយន្តការ រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ ។ ទោះបីជាយ៉ាងនេះក្តី ក្រសួង ស្ថាប័ន រាជធានី និងខេត្តមួយចំនួន បានផ្លាស់ប្តូរថ្នាក់ដឹកនាំ និងមន្ត្រីអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចាំបាច់ត្រូវមាន ការរៀបចំកែសម្រួលយន្តការឡើងវិញ និងត្រូវទទួលការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពជាថ្មីបន្ថែមទៀត ដើម្បីបន្តអនុវត្តឱ្យរលូន និងទទួលបានប្រសិទ្ធភាព ។ អង្គការដៃគូជាតិ អន្តរជាតិ និងផ្នែកឯកជនក៏ជាអ្នកពាក់ព័ន្ធដែលបានចូលរួមចំណែកយ៉ាងច្រើនក្នុងការផ្តល់យោបល់ ចែករំលែក បទពិសោធន៍ ធនធាន បច្ចេកទេស ព្រមទាំងបានធ្វើសកម្មភាពដោយផ្ទាល់នៅតាមបណ្តាគោលដៅគ្រោងទុក ដែលអាចទទួលយកសម្រាប់ជាធាតុចូលក្នុងការកសាងផែនការនេះ ។ ការរកឃើញនូវចំណុចខ្វះខាត និងភាពប្រឈម ក្នុងអំឡុងពេលពាក់កណ្តាលអាណត្តិទី១នៃផែនការ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ បានបង្ហាញនូវ គ្រប់យុទ្ធសាស្ត្រដែលចាំបាច់ត្រូវកែលម្អ[5] ។

[5] មានក្នុងឧបសម្ព័ន្ធ៣




## ២.៤. បច្ចុប្បន្នភាពនៃស្ថានភាព ឆ្នាំ២០១៧ និង២០១៨

បញ្ហាគន្លឹះមួយចំនួនដែលកើតមានក្នុងឆ្នាំ២០១៧ និងអាចអូសបន្លាយដល់ឆ្នាំ២០១៨ ដូច្នេះចាំបាច់ត្រូវរកដំណោះស្រាយតាមរយៈសកម្មភាពជាអាទិភាពមួយចំនួន ដូចខាងក្រោម ៖

**១. បញ្ហាប្រឈម និងដំណោះស្រាយសម្រាប់ពលករនៅប្រទេសគោលដៅ ៖**

- ពលករកម្ពុជា ក៏ដូចជាពលករពីប្រទេសមួយចំនួនដែរ (ហ្វីលីពីន ឥណ្ឌូណេស៊ី ភូមា ឡាវ វៀតណាម បង់ក្លាដែស...) បាននាំគ្នាធ្វើចំណាកស្រុកទៅធ្វើការក្នុងប្រទេសជិតខាង ជាពិសេសក្នុងប្រទេសថៃ ប្រទេសម៉ាឡេស៊ី សាំងហ្គាពួរ...រាប់លាននាក់ ដែលក្នុងនោះ ពលករភាគច្រើនជាពលករគ្មានជំនាញ ឬមានជំនាញទាបហើយទៅធ្វើការតាមបែបជាប់លាប់ និងតាមរដូវកាល ឬប្រចាំថ្ងៃ ។
- ចាប់ពីខែមិថុនា ឆ្នាំ២០១៧ ក្រោយពីការប្រកាសអំពីការពង្រឹងការអនុវត្តច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍ថៃ ពលករកម្ពុជាដែលគ្មានឯកសារច្បាប់ បានចុះបញ្ជីក្រសួងការងារថៃប្រមាណ១.០៥០០០០នាក់ និងត្រូវបានទទួលភាពស្របច្បាប់ក្នុងប្រទេសថៃក្រោមកិច្ចសហការរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ រួមមានការផ្តល់លិខិតឆ្លងដែន (ក្រសួងមហាផ្ទៃកម្ពុជា) ឬសៀវភៅឆ្លងដែនរកការងារ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា) ដោយឆ្លាប់ជាមួយទិដ្ឋាការពីស្ថានទូតថៃ ការផ្តល់ប័ណ្ណអនុញ្ញាតស្នាក់នៅ និងប័ណ្ណអនុញ្ញាតឱ្យធ្វើការងារ (ក្រសួងការងារថៃ) ជាដើម ។
- ក្នុងឆ្នាំ២០១៨ មានពលករប្រមាណជាងមួយលាននាក់បាន និងកំពុងធ្វើការងារក្នុងប្រទេសថៃ ពលករប្រមាណ ៥០.០០០នាក់បាននិងកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី និងប្រមាណជា ១០.០០០នាក់ទៀត កំពុងធ្វើការនៅប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសផ្សេងទៀតក្នុងតំបន់ ។
- ពលករដែលចូលទៅប្រទេសគោលដៅដោយខុសច្បាប់ ឬប្រើប្រាស់ឯកសារក្លែងក្លាយ ឬហួសសុពលភាពត្រូវបានសមត្ថកិច្ចប្រទេសគោលដៅចាប់ឃាត់ខ្លួន ឬដាក់ទោសទណ្ឌ ឬបញ្ជូនត្រឡប់មកកម្ពុជាវិញ ។

- នៅមានពលករមួយចំនួនទៀត មិនទាន់បានចុះបញ្ជី និងមិនទទួលបានឯកសារស្របច្បាប់នៅឡើយ ហើយបន្តសម្ងំលាក់ខ្លួន ដោយមានការជួយជ្រោមជ្រែងពីថៅកែ ឬមេខ្យល់ ដើម្បីឱ្យធ្វើការងារបណ្ដោះអាសន្នដោយរង់ចាំទទួលតាពស្របច្បាប់ក្នុងប្រទេសថៃ ។
- ពលករដែលបានចុះបញ្ជី ឬមានឯកសារហើយ ក៏ត្រូវផុតសុពលភាពទៅវិញជាបន្តបន្ទាប់ ដែលនឹងជំរុញឱ្យក្លាយជាពលករខុសច្បាប់ដដែល ។
- កុមារក្នុងគ្រួសារ ដែលទៅនៅជាមួយឪពុកម្ដាយ ក៏ប្រឈមនឹងបញ្ហាខ្វះឯកសារអត្តសញ្ញាណ និងមិនបានរៀនសូត្រត្រឹមត្រូវ ដូចកុមារដទៃដែរ ។
- កុមារកម្ពុជាជាច្រើនបានកើតនៅក្នុងប្រទេសគោលដៅ មិនបានចុះបញ្ជីអត្រានុកូលដ្ឋានកំណើត មិនទាន់បានបញ្ជាក់សញ្ជាតិ គ្មានលំនៅដ្ឋានក្នុងប្រទេសដើម (កម្ពុជា) ព្រោះឪពុកម្ដាយមួយចំនួន ធ្វើចំណាកស្រុកយូរឆ្នាំ និងបានផ្ដល់កំណើតឱ្យកូននៅក្រៅប្រទេស មួយហើយ មួយទៀត ។
- អវត្តមានយូរឆ្នាំនៅក្រៅប្រទេសដោយមិនត្រឡប់មកស្រុកកំណើតវិញ បានធ្វើឱ្យពលករបាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង ដីធ្លី ដោយសារការលក់យកប្រាក់ដោះស្រាយការខ្វះខាត ឬការសងបំណុល ឬការរំលោភបំពានដកហូតដោយបងប្អូន អ្នកជិតខាង ឬអាជ្ញាធរ អាស្រ័យដោយការបាត់ដំណឹងជាច្រើនឆ្នាំដែលជាមូលហេតុមិនអាចឱ្យពួកគាត់ត្រឡប់មករស់នៅក្នុងស្រុកទេសវិញបាន ។
- ទោះបីជាពួកគាត់មិនចង់ ឬមិនអាចត្រឡប់មកវិញដោយខ្លួនឯង តែទីបំផុតពួកគាត់នៅតែត្រូវត្រឡប់មកប្រទេសខ្លួនវិញ ឬត្រូវគេបញ្ជូនត្រឡប់ដដែល ព្រោះគាត់មិនមានសញ្ជាតិក្នុងប្រទេសគោលដៅ ។ ក្មេងទាំងនោះគ្មានភាសា វប្បធម៌ ដូចកុមារដែលរស់នៅក្នុងប្រទេសដើមឡើយ ។ ការផ្ដល់អត្តសញ្ញាណ ឬការធ្វើសមាហរណកម្ម គឺជាបញ្ហាចម្បងសម្រាប់កុមារដែលមិនចេះភាសាជាតិកំណើត មិនមានសាច់ញាតិទាំងនោះ និងត្រូវប្រឈមនឹងការទទួលបានការសិក្សាអប់រំ និងសិទ្ធិមូលដ្ឋានដទៃទៀត ។
- មានពលករជាច្រើន ចូលទៅធ្វើការប្រចាំថ្ងៃ ឬតាមរដូវកាល នៅតាមកសិដ្ឋាន ដែលនៅបណ្ដោយព្រំដែនកម្ពុជា ថៃ ដែលមិនទាន់គ្រប់គ្រងបាន និងមួយចំនួន បានបង្ហួសទៅធ្វើការខុសច្បាប់នៅក្នុងខេត្តផ្សេងដែលប្រឈមនឹងការចាប់បញ្ជូនត្រឡប់ និងការចោទប្រកាន់ផ្សេងៗ ។

**២. បញ្ហាពលករដែលត្រូវបានបញ្ជូនត្រឡប់ ឬវិលត្រឡប់ ៖**

- ការបញ្ជូនត្រឡប់នូវកម្លាំងដែលអសមត្ថភាពពលកម្មដូចជា៖ មនុស្សវ័យចំណាស់ ជនពិការ អ្នកញៀនថ្នាំមានវិបល្លាស អ្នកជម្ងឺ អ្នករបួសត្រូវព្យាបាលរយៈពេលយូរ ឬអ្នកដែលមានគ្រោះថ្នាក់ ស្លាប់ បាត់បង់ជីវិត ...។ល។ ត្រូវការជំនួសដោយកម្លាំងថ្មីដើម្បីបំពេញសង្វាក់ផលិតកម្ម ។ ដូច្នេះការជ្រើសរើសប្រមែប្រមូល

កម្លាំងថ្មីឱ្យចូលទៅជំនួសកន្លែងដែលខ្វះកម្លាំងពលកម្មក្នុងខ្សែសង្វាក់ផលិតកម្ម គឺមានជាហូរហែ ដើម្បីរក្សាតុល្យភាពនៃផលិតកម្ម និងចំនួនពលករ ដែលត្រូវការក្នុងប្រទេសគោលដៅ ។

- ហេតុនេះ នៅពេលសេចក្តីត្រូវការត្រូវបានបំពេញគ្រប់គ្រាន់ ប្រទេសគោលដៅអាចរក្សាចំនួនពលករឱ្យនៅថេរ ឬមានកំណើនតិចតួច ប៉ុន្តែមានតែចំនួនប៉ុណ្ណោះដែលអាចផ្លាស់ប្តូរតិចតួច ឯមនុស្សត្រូវ បានផ្លាស់ប្តូរ ។ ក្នុងនោះ ប្រទេសគោលដៅនឹងរក្សាទុកតែកម្លាំងណាដែលប្រើការបានតែប៉ុណ្ណោះ ។ ឯប្រទេសដើម ឬប្រទេសបញ្ជូន បានទទួលត្រឡប់ទៅវិញនូវកម្លាំងដែលសេសសល់ពីការប្រើប្រាស់ ដែលអសមត្ថភាពពលកម្ម ហើយត្រូវបញ្ជូនកម្លាំងដែលពេញលេញទៅបម្រើការនៅក្នុងប្រទេសគោលដៅបន្តទៀត ។
- ***ហេតុនេះហើយ បានជាការទ្រទ្រង់នូវប្រព័ន្ធរបបសោធនសន្តិសុខសង្គម គឺជារឿងចាំបាច់ ដែលប្រទេសបញ្ជូនត្រូវរ៉ាប់រង[6] និងត្រូវការជាចាំបាច់នូវការគាំទ្រ និងកិច្ចសហការពីប្រទេសគោលដៅ ។***

ដោយឡែក រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យដំណើរការនូវរបបហានិភ័យការងារ របបថែទាំសុខភាព និងរបបសោធននិវត្តន៍ដែលគ្របដណ្តប់លើសហគ្រាស គ្រឹះស្ថាន ផ្នែកផលិតកម្ម ផ្នែកសេវាកម្ម និងផ្នែកសាធារណៈ ស្ទើរតែ១០០%នៃកម្មករនិយោជិត និងមន្ត្រីសាធារណៈ ។ ទន្ទឹមនឹងនេះ កម្ពុជាបានរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមនៅឆ្នាំ២០១៨ កន្លងទៅនេះ ដើម្បីពង្រីកវិសាលភាពបន្ថែម ដល់ប្រជាពលរដ្ឋដែលប្រកបរបរស្វ័យនិយោជន៍ និងពលករទេសន្តរប្រវេសន៍ផងដែរ។

តាមរយៈរបបសន្តិសុខសង្គមកម្ពុជានឹងមានប្រព័ន្ធគាំពារសង្គមមួយកាន់តែប្រសើរឡើង ដែលជួយដល់ការអភិវឌ្ឍ សុខុមាលភាពសង្គមជូនដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងធ្វើឱ្យសង្គមកាន់តែមានសមធម៌ ។

តម្រូវការពលករគ្មានជំនាញ និងមានជំនាញទាប គឺជាភាពប្រឈមរបស់ប្រទេសបញ្ជូន ក្នុងការកសាង និងអភិវឌ្ឍន៍ជំនាញដល់ពលករ ។ ព្រមជាមួយនោះ ពលករបានទទួលកម្រៃទាប មានភាពប្រឈមគ្រោះថ្នាក់ខ្ពស់ និងមិនមានតុល្យភាពរវាងចំណូល និងចំណាយ ជាពិសេស ចំណាយសង្គមដែលមានកម្រិតខ្ពស់ ដែលមិនអាចប្រៀបធៀបបានរវាងគុណប្រយោជន៍ដែលទទួលបានជាប្រាក់ចំណូលការងារ និងការចំណាយជាសេចក្តីត្រូវការចាំបាច់សម្រាប់សុវត្ថិភាពរបស់ពលករ និងផលវិបាកដែលជះឥទ្ធិពលដល់កុមារ គ្រួសារ និងសង្គម យ៉ាងធំធេងនោះបានឡើយ ។ ផលវិបាកទាំងនោះ រួមមានៈ

- ការវិលត្រឡប់ ឬបញ្ជូនត្រឡប់ ទាំងរាងកាយ របួស ពិការ
- ការវិលត្រឡប់ក្នុងភាពចាស់ជរា មានជម្ងឺប្រចាំកាយ ញៀនថ្នាំ ស្មារតីវិបល្លាសបាក់កម្លាំង បាត់បង់សមត្ថភាពពលកម្ម
- ការត្រឡប់មកវិញដោយគ្មានជំនាញ ការងារ ឬអាជីពសម្រាប់ការរស់នៅ

[6] តាំងពីឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមបង្កើតគោលនយោបាយ និងច្បាប់ ដើម្បីអនុវត្តការផ្តល់របបសេវាសន្តិសុខសង្គម រួមមានការព្យាបាលក្នុងគ្រោះថ្នាក់ការងារ របបសោធននិវត្តន៍ដល់ពលករ ពលការិនី ការផ្តល់សេវាជាកញ្ចប់ សម្រាប់ពេលមានផ្ទៃពោះ លំហែមាតុភាព និង ការឧបត្ថម្ភមាតា និងទារក ដល់អាយុពីរឆ្នាំ ...។ល។ មានរៀបរាប់ក្នុងឧបសម្ព័ន្ធ៤ ។

- ○ បន្ទុកបន្ថែមលើគ្រួសារដែលគ្មានសេសសល់ទ្រព្យសម្បត្តិ ផ្ទះសម្បែង ឬដីធ្លី ព្រោះតែការធ្វើចំណាកស្រុកច្រើនឆ្នាំ ដោយគ្មានទំនាក់ទំនង
- ○ ពលករ និងកុមារដែលរស់នៅប្រទេសគោលដៅច្រើនឆ្នាំ ឬកើតធំធាត់នៅប្រទេសគោលដៅ មិនមានឯកសារបញ្ជាក់អត្តសញ្ញាណ មិនចេះភាសាជាតិ មិនមានញាតិសន្តានក្នុងស្រុក
- ○ អ្នកជាប់ឃុំច្រើនឆ្នាំ មិនមានដំណឹង មិនបានធ្វើការងារ និងមិនមានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ
- ○ អ្នកស្លាប់ អ្នកបាត់ខ្លួន បាត់ដំណឹង អស់រយៈពេលច្រើនឆ្នាំ ត្រូវស្វែងរក
- ○ តម្រូវការផ្តល់យុត្តិធម៌ ក្នុងរឿងក្តីវិវាទការងារ ការកេងប្រវ័ញ្ច រំលោភសិទ្ធិ គ្រោះថ្នាក់ការងារ ការងារបង្ខិតបង្ខំ ការជួញដូរកម្លាំងពលកម្ម ការជួញដូរមនុស្ស និង ការប្រើប្រាស់ពលករក្នុងទម្រង់ជាទាសភាព ។ល។

**៣. តម្រូវការដោះស្រាយបញ្ហាកុមារ ក្នុងសហគមន៍ ៖**

- គ្រួសារដែលមានសមាជិកទៅធ្វើការឆ្ងាយ ឬមានឪពុកម្តាយបាត់ដំណឹងយូរខែឆ្នាំ ឬមានគ្រោះថ្នាក់បាត់បង់ជីវិត ឬត្រូវបានរងគ្រោះ ឬត្រូវជាប់ឃុំក្នុងប្រទេសគោលដៅ ឬបាត់បង់សមត្ថភាពពលកម្ម តែងតែខ្វះអ្នកជួយផ្គត់ផ្គង់ ឬបានបន្ថែមបន្ទុក ។
- ពលករជាច្រើន បានទុកកូនរបស់ខ្លួននៅជាមួយឪពុក ម្តាយ ជីដូន ជីតា ឬសាច់ញាតិ ឬអ្នកជិតខាង ដែលពេលខ្លះ ទុកកូនឱ្យនៅតែជាមួយបងប្អូនតូចៗ ដែលមិនអាចមើលថែគ្នាបាន ។ ក្មេងទាំងនោះ មិនអាចមានលទ្ធភាពបានរៀនសូត្រ ឬថែទាំសុខភាព ឬមានម្ហូបអាហារគ្រប់គ្រាន់នោះទេ ។
- កុមារទាំងនេះប្រឈមនឹងការបោះបង់ពីឪពុកម្តាយ ឬអាណាព្យាបាលដែលមានលទ្ធភាព ហើយច្រើនតែរងផលប៉ះពាល់ពីអំពើហិង្សា ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ការជួញដូរនិងកេងប្រវ័ញ្ចកម្លាំងពលកម្ម ការបញ្ជូនទៅធ្វើការបម្រើតាមផ្ទះ ការសុំទានដោយមានអ្នកកេងប្រវ័ញ្ច ការជួលឱ្យលក់ផ្កា ឬទំនិញតាមដងផ្លូវ ជាក្មេងអនាថាត្រូវបានជ្រើសរើសឱ្យចែកចាយ និងប្រើប្រាស់គ្រឿងញៀន ត្រូវបានអូសទាញឱ្យធ្វើសកម្មភាពខុសច្បាប់ដទៃទៀតជាដើម ដើម្បីទទួលបានប្រាក់កម្រៃចិញ្ចឹមជីវិត ដែលប្រឈមនឹងគ្រោះថ្នាក់គ្រប់រូបភាព ឬទទួលទោសទណ្ឌថែមទៀត។
- កុមារមួយចំនួនបានចាកចេញដោយខ្លួនឯង តាមការអូសទាញពីមេខ្យល់ ឬមិត្តភក្តិចោលឪពុកម្តាយ ។ ពេលទៅដល់ប្រទេសគោលដៅ ក្មេងទាំងនោះប្រឈមនឹងការកេងប្រវ័ញ្ចគ្រប់រូបភាព ជាពិសេសពិបាកក្នុងការជួយគាំពារផ្នែកច្បាប់ ព្រោះគ្មានលិខិតបញ្ជាក់អត្តសញ្ញាណ មិនចេះភាសាជាតិ មិនស្គាល់ភូមិស្រុក ញាតិសន្តាន ។

- បញ្ហាទាំងនេះ ក៏ជាបន្ទុកសម្រាប់អាជ្ញាធរ ឬសមត្ថកិច្ចក្នុងមូលដ្ឋាន ដែលត្រូវដោះស្រាយ រួមទាំងការបង្ការ ទប់ស្កាត់ ការអប់រំ ការការពារ និងការជួយឧបត្ថម្ភគាំទ្រ ដែលមិនអាចបណ្ដែតបណ្ដោយឱ្យកុមារទាំងនោះ ខ្វះការគ្រប់គ្រងបានឡើយ ។

**៤. ការគ្រប់គ្រងកម្លាំងពលកម្ម ដែលមានសក្ដានុពលសម្រាប់ការធ្វើទេសន្ដរប្រវេសន៍ និងកម្លាំងសម្រាប់បំពេញឱ្យតម្រូវការការងារក្នុងស្រុក ៖**



- កម្លាំងនេះ ជាយុវវ័យ ដែលមាននៅតាមសហគមន៍ ជាគ្រួសារ នៅតាមជនបទ និងសហគមន៍តាមព្រំដែន និងនៅសាលារៀន ។
- កម្លាំងទាំងនោះ ត្រូវការការអប់រំ និងការគ្រប់គ្រងយ៉ាងហ្មត់ចត់ ពីអាជ្ញាធរ សមត្ថកិច្ច អ្នកគ្រប់គ្រងសហគមន៍ និងសាលារៀន ដើម្បីអាចបញ្ចៀសបានពីការលុះក្នុងល្បិចកល មេខ្យល់ និងអ្នកអូសទាញ ។
- កម្លាំងទាំងនោះ ត្រូវការព័ត៌មានទីផ្សារការងារ មុខរបរ ការណែនាំតម្រង់ទិស ការផ្ដល់ប្រឹក្សា សមត្ថភាពជំនាញ ឯកសារការងារតាមច្បាប់ត្រឹមត្រូវ និងការធានាសុវត្ថិភាព និងផលប្រយោជន៍ក្នុងការងាររបស់ខ្លួន ទោះជានៅក្នុងស្រុក ឬនៅក្រៅប្រទេសក៏ដោយ ។

**៥. ពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ និងអំពើពាក់ព័ន្ធ ៖**

- ការរីកឡើងវិញនៃសេវាកំសាន្តសប្បាយដែលបង្កប់សេវាផ្លូវភេទ
- ការជេីរំលោភផ្លូវភេទនៅតែបន្តកើតមាន ជាពិសេសលើអនីតិជន ដែលត្រូវបានរកឃើញ និងបង្ក្រាប

- ករណីនៃការពពោះជំនួសដើម្បីនាំទារកចេញដោយខុសច្បាប់ ជាបទល្មើសថ្មីដែលកើតមាន ដែលពាក់ព័ន្ធដល់ការលក់ ឬការរត់ពន្ធ ឬការជួញដូរទារក ឬបោះបង់ទារក
- ការនាំចេញស្ត្រីវ័យក្មេង តាមរយៈការស្វែងរកគូស្រករ ឬអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ដែលនាំឱ្យមានការរំលោភបំពាន ឬជួញដូរផ្លូវភេទ ។

## ខ.៥. ទិសដៅសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅចំនួន ២៤ចំណុច ដើម្បីជាមូលដ្ឋាននៃការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ដែលចេះតែកើតមានមិនឈប់ឈរ [7] ។ ទិសដៅទាំងនោះ ត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិ ក្រុមការងារអន្តរស្ថាប័នទាំង០៦ ក្រសួងស្ថាប័នពាក់ព័ន្ធជាសមាជិក និងរាជធានីខេត្តទាំង២៥ ។



## ខ.៦. គម្រោងសកម្មភាពក្រសួងស្ថាប័ន

ក្រសួងស្ថាប័ននីមួយៗសុទ្ធតែបានគ្រោងទុកជាសកម្មភាពក្នុងផែនការរបស់ខ្លួនដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមជំនាញវិស័យរៀងៗខ្លួន ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះ ការអនុវត្តច្បាប់ និងការរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា ។ សកម្មភាពទាំងនោះ ត្រូវបានប្រមូលដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ ដែលជាផែនការរួម សម្រាប់ការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

[7] មានលម្អិតក្នុង ឧបសម្ព័ន្ធ៥

ដែលមានលក្ខណៈជាកិច្ចសហប្រតិបត្តិការរួមគ្នា កាត់បន្ថយភាពចកល្បែង និងធ្វើឡើងព្រមៗគ្នា មិនត្រួតជាន់គ្នា ដែលនាំឱ្យខាតបង់ធនធាន ។

## ខ.៧. មេរៀន បទពិសោធន៍ និងការអនុវត្តល្អៗ

តាមរយៈការធ្វើបច្ចុប្បន្នភាព និងកែលម្អនៃផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមក មេរៀន បទពិសោធន៍ទាំងឡាយត្រូវបានដាក់បញ្ចូល ក្នុងគោលគំនិត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ។ ក្នុងនោះ ការវាយតម្លៃរបស់សហរដ្ឋអាមេរិកប្រចាំឆ្នាំ ជាពិសេសក្នុងឆ្នាំ២០១៨ និងផែនការសកម្មភាពអាស៊ាន បានជួយជំរុញឱ្យមានការយកចិត្តទុកដាក់បន្ថែម ទៀតក្នុងការលើកសកម្មភាព បំពេញចន្លោះខ្វះខាត ។

- **អនុសាសន៍សហរដ្ឋអាមេរិកក្រោយការវាយតម្លៃប្រចាំឆ្នាំ២០១៨ ៖**

ទន្ទឹមនឹងចំណាត់ថ្នាក់លេខ២ បីឆ្នាំជាប់គ្នា ដែលសហរដ្ឋអាមេរិកបានធ្វើការវាយតម្លៃ និងធ្វើចំណាត់ថ្នាក់លើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាកន្លងមក ការវាយតម្លៃនៅឆ្នាំ២០១៩ បែរជាចាត់កម្ពុជាចូលក្នុងចំណាត់ថ្នាក់លេខ២ក្នុងការឃ្លាំមើលទៅវិញ បើទោះបីជាលទ្ធផលនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជា ទាំងការបង្ការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោស កិច្ចការពារជនរងគ្រោះ និងកិច្ចសហការក្នុងការដោះស្រាយបញ្ហា ជាមួយប្រទេសពាក់ព័ន្ធ បានប្រសើរជាងឆ្នាំមុនៗយ៉ាងណាក៏ដោយ[8] ។ ការវាយតម្លៃហាក់ដូចជាមិនបានផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងពិតប្រាកដ របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយក៏បង្ហាញពីភាពលម្អៀង មិនយុត្តិធម៌ និងមិនលើកទឹកចិត្តដល់គ្រប់អ្នកពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផងដែរ ។

ទោះបីជាយ៉ាងនេះក្តី ក្នុងនាមជាអាជ្ញាធររដ្ឋ ដែលទទួលខុសត្រូវលើកិច្ចការពារសុវត្ថិភាពប្រជាជនរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តកិច្ចខិតខំប្រឹងប្រែងមិនរួញរា និងបាក់ស្មារតីឡើយ ។ ផ្ទុយទៅវិញ សំណូមពរ និងអនុសាសន៍[9]ទាំងឡាយ ត្រូវបានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលយកមកពិចារណា និងពិនិត្យដាក់បញ្ចូលក្នុងសកម្មភាពនៃផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំ ដើម្បីជំរុញការអនុវត្តបំពេញភាពខ្វះចន្លោះក្នុងកិច្ចប្រតិបត្តិការផងដែរ ។

- **ផែនការសកម្មភាព អាស៊ាន**

បញ្ហាប្រឈម៖

១. **ភាពអសកម្ម៖** អំពើពុករលួយ គម្លាតសេដ្ឋកិច្ច និងភាពក្រីក្រ កំរិតនៃការអភិវឌ្ឍ អស្ថេរភាពសេដ្ឋកិច្ច ប្រព័ន្ធ និងការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព តម្រូវការផ្គត់ផ្គង់រាល់ទម្រង់ធ្វើអាជីវកម្ម .. បង្កឱ្យមានភាពងាយរងគ្រោះ ។

---

[8] គ្រាន់តែ៦ខែដើមឆ្នាំ២០១៩ ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបាន **៧៨ករណី** លើ៦២ករណី (កើនឡើង **១៦**ករណី ស្មើនឹង ២៥%) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៩៧**នាក់/**៨៥**នាក់ (កើន១២នាក់ ស្មើនឹង ១៤%) ក្នុងនោះស្រី **២២**នាក់ អនីតិជន **០៩**នាក់ ជាជនបរទេស **១៤**នាក់ សញ្ជាតិចិន **១២**នាក់ និងអាមេរិក **០២**នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន **២៦៣**នាក់ (លើ**១០៦**នាក់) កើន១៥៧នាក់ ស្មើនឹង១៤៨% ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ **៧០**នាក់ អាយុ១៥-១៧ឆ្នាំ **៣១**នាក់ និងពី១៨ឆ្នាំឡើង **១៦២**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **៧២**នាក់ និងប្រគល់ទៅគ្រួសារ **១៩១**នាក់) ។

[9] មានក្នុងឧបសម្ព័ន្ធ៦

២. **ប្រព័ន្ធច្បាប់៖** ខ្វះដោយអន្លើ ជាពិសេសរវាងប្រទេសដែលពាក់ព័ន្ធ ការអនុវត្តមិនទាន់មានប្រសិទ្ធភាព ។

៣. **លើកកំពស់សមត្ថភាពមន្ត្រី៖** សមត្ថភាព និងនីតិវិធី សម្រាប់មន្ត្រីជួរមុខ ដើម្បីចាប់រកឃើញ ទប់ស្កាត់បម្លាស់ទីរបស់ជនរងគ្រោះទៅកាន់ប្រទេសគោលដៅ ។

៤. **កំណត់អត្តសញ្ញាណ៖** បែបបទ នីតិវិធីកំណត់អត្តសញ្ញាណជនល្មើស និងជនរងគ្រោះត្រូវធ្វើឱ្យបានត្រឹមត្រូវ និងផ្តល់កិច្ចការពារឱ្យសមស្រប ។

៥. **កែលម្អការស៊ើបអង្កេត៖** ជំរុញការស៊ើបអង្កេតឱ្យទាន់ពេល រកឱ្យឃើញ និងផ្តន្ទាទោសឱ្យត្រឹមត្រូវតាមច្បាប់ ពិសេសទាក់ទងនឹងរឿងក្តីស្មុគស្មាញ ។

៦. **ទំនាក់ទំនង៖** លើកកម្ពស់ទំនាក់ទំនង និងសម្របសម្រួលផ្ទាល់រវាងនិងក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច និងអន្តរជាតិ ។

៧. **យន្តការ៖** ដើម្បីអនុវត្តច្បាប់ ចាំបាច់ត្រូវបង្កើតយន្តការចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ។

ទន្ទឹមនឹងនោះដែរ អាស៊ាន បានដាក់ចេញនូវសកម្មភាពជាច្រើន ដែលប្រទេសជាសមាជិកគប្បីយកចិត្តទុកដាក់ អនុវត្តសកម្មភាពជាអាទិភាព តាមយុទ្ធសាស្ត្រនីមួយៗ[10] ។

[10] មានលម្អិតក្នុងឧបសម្ព័ន្ធ៧

## គ. ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

### គ.១. ទស្សនៈវិស័យ

*"ព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព សមភាព យុត្តិធម៌ និងការអភិវឌ្ឍ ដោយការពារប្រជាពលរដ្ឋយ៉ាងពេញទំហឹងពីរាល់ទម្រង់នៃអំពើជួញដូរ និងការធ្វើអាជីវកម្មលើមនុស្ស ក្នុងប្រទេសកម្ពុជា និងលើប្រជាជនកម្ពុជា ទោះជានៅទីណាក៏ដោយ" ។*

### គ.២. បេសកកម្ម

ដឹកនាំ សម្របសម្រួល ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិ ដើម្បីរួមគ្នាជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ធ្វើការបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ប្រយុទ្ធប្រឆាំងរាល់ទំរង់នៃអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច និងអំពើពាក់ព័ន្ធដទៃទៀត ដែលបំផ្លាញសេចក្តីសុខ ផលប្រយោជន៍ គុណតម្លៃ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិទាំងបុរស ស្ត្រី កុមារ យុវវ័យ ដែលជាធនធានសង្គម វប្បធម៌ និង សេដ្ឋកិច្ចជាតិ ។

### គ.៣. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងអំពើជួញដូរមនុស្ស (ឆ្នាំ២០១៩-២០២៣)

ឯកសារគោល សម្រាប់ផែនការសកម្មភាព ២០១៧-២០១៨ គឺជាមូលដ្ឋាន គ្រឹះសម្រាប់ការកសាងឯកសារផែនការយុទ្ធសាស្ត្រជាតិ៥ ឆ្នាំ២០១៩-២០២៣ នេះ ។ ឯកសារនេះ បានបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ នៅពាក់កណ្តាលអាណត្តិទី១នៃផែនការដែលជាម៉ែត្រវាស់ និងជាតំណាក់កាលដ៏សំខាន់ក្នុងដំណើរការនៃការរៀបចំយុទ្ធសាស្ត្រដ៏ទូលំទូលាយ ធានាដល់និរន្តរភាពនៃយន្តការ សកម្មភាព និងកិច្ចអន្តរាគមន៍ទាំងឡាយ ដែលបានធ្វើឡើងដោយមានការឯកភាពគ្នា ។ ផែនការយុទ្ធសាស្ត្រជំហានទី២នេះ នឹងដើរតួនាទីសំខាន់ជាផែនទីនាំផ្លូវសម្រាប់ការកំណត់សកម្មភាពជាអាទិភាពក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទក្នុងប្រទេសកម្ពុជា និងលើពលរដ្ឋកម្ពុជា នៅក្រៅប្រទេស ។

គណៈកម្មាធិការជាតិ បានផ្តោតការយកចិត្តទុកដាក់ និងដាក់បញ្ចូលទៅក្នុងផែនការផងដែរនូវគម្រោងការនានារបស់អង្គការដៃគូ និងសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធនឹងយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្សទាំងស្ត្រី បុរស និងកុមារ ។

ដោយឡែក បណ្តាប្រទេសក្នុងអាស៊ានត្រូវបានចាត់ទុកថាជាប្រទេសប្រភព ឬប្រទេសឆ្លងកាត់(សំចត) និងជាប្រទេសគោលដៅ ដែលក្នុងនោះ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងពិធីសារបន្ថែម (ប៉ាឡឺម៉ូ) បានផ្តោតលើការបង្ការ-ទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ប្រជាជនគ្រប់វ័យ គ្រប់ពណ៌សម្បុរ ឋានៈ ជាតិសាសន៍ ពីអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ

ដែលមានគោលដៅកេងប្រវ័ញ្ចដោយទុច្ចរិត និងមានប្រភេទសំខាន់ៗជាអាទិ៍ ៖ (១)អំពើលក់ដូរមនុស្ស (២)អំពើជួញដូរផ្លូវភេទ (៣) អំពើជួញដូរពលកម្ម (៤) អំពើជួញដូរសរីរាង្គ ។

ដើម្បីអនុវត្តលិខិតូបករណ៍ និងផែនទីបង្ហាញផ្លូវ ASEAN ព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាចិត្តចូលរួមធ្វើសហប្រតិបត្តិការ អនុវត្តតាមអភិក្រម ដើម្បីដំណោះស្រាយ គ្រប់ជ្រុងជ្រោយ ក្នុងការបង្ការ-ទប់ស្កាត់ បង្ក្រាប ដាក់ទោសរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើជួញដូរសរីរាង្គរបស់មនុស្ស ។

ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ របស់ព្រះរាជាណាចក្រកម្ពុជា បានរៀបចំក្នុងគោលគំនិតស្របគ្នាទៅនឹងផែនការសកម្មភាពអាស៊ាន ដែលបម្រើឱ្យការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្សពិសេសស្ត្រី និងកុមារ (ACTIP) សម្រាប់ភាពជាក់លាក់នៃការអនុវត្តគោលការណ៍ច្បាប់ គោលនយោបាយនៃប្រទេសសមាជិកអាស៊ានផងដែរ ។

មិនតែប៉ុណ្ណោះ ផែនការយុទ្ធសាស្ត្រនេះ ក៏បានរៀបចំសមស្របទៅតាមបរិបទនៃកត្តិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលកម្ពុជាបានចូលរួមអនុម័ត នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេសម៉ារ៉ុកផងដែរ ។

ដូច្នេះ ផែនការយុទ្ធសាស្ត្រជាតិនេះបានដាក់បញ្ចូលនូវរាល់ខ្លឹមសារ សេចក្តីត្រូវការ និងគោលការណ៍ជាអាទិភាពទាំងឡាយ ព្រមទាំងជំរុញការអនុវត្តអនុសញ្ញា និងផែនការអាស៊ាន និងរាល់សំណូមពរទិសដៅការងារទាំងឡាយឱ្យមានប្រសិទ្ធភាពតាមការរំពឹងទុក ។

## គ.៤. គុណតម្លៃស្នូលនៃផែនការសកម្មភាពជាតិ

### ✓ ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើផែនការសកម្មភាពជាតិ

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសកម្មភាពអាទិភាពមួយ ដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ និងជំរុញសកម្មភាពតាមរយៈការគ្រោងទុកនូវធនធានមនុស្ស ធនធានថវិកា និងសម្ភារៈឧបករណ៍បម្រើឱ្យការងារប្រតិបត្តិការ ។ ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ នេះ គឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាយន្តការស្នូល និងផ្អែកលើការធ្វើតុល្យភាពរវាងចំណាយ និងលទ្ធផលនៃកិច្ចប្រតិបត្តិការដោយបង្កើន ប្រសិទ្ធភាពឆ្លើយតបឱ្យចំទិសដៅ ។ នេះគឺជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដោយបានផ្តល់កិច្ចសហការយ៉ាងទូលំទូលាយ និងការចូលរួមគាំទ្រពីដៃគូពាក់ព័ន្ធ ដែលរួមមានអង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ។ រាជរដ្ឋាភិបាលមានភារកិច្ចដោះស្រាយកំណើននៃតម្រូវការធនធានមនុស្ស និងហិរញ្ញវត្ថុដើម្បីអនុវត្ត និងធ្វើឱ្យសម្រេចផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពប្រចាំឆ្នាំដែលបានរៀបចំដោយគ្រោងទុកនូវថវិកាជាតិ និងកៀរគរការចូលរួមពីបណ្តាដៃគូ ដែលមានគោលដៅនៃប្រតិបត្តិការរួមគ្នា ដើម្បីបំពេញ និងពង្រីកសកម្មភាពដែលចាំបាច់ ។

### ✓ គោលការណ៍គោរពសិទ្ធិមនុស្សជាមូលដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា បានបន្តប្តេជ្ញាចិត្ត ការពារ និងគោរពសិទ្ធិមនុស្ស លើកកម្ពស់សុខុមាលភាពសុវត្ថិភាពរបស់ប្រជាជនទូទាំងប្រទេសកម្ពុជា ជាពិសេសចំពោះជនរងគ្រោះ ឬជនងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកជាស្នូលនៃសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ជនរងគ្រោះ

គ្រប់ភេទ គ្រប់វ័យនៃអំពើជួញដូរមនុស្ស ត្រូវបានស្វែងរកដោយការកំណត់អត្តសញ្ញាណជាក់លាក់ ដើម្បីការពារសុវត្ថិភាព ពង្រីកលទ្ធភាពក្នុងការទទួលបានព័ត៌មាន និងសេវាសង្គមរួមទាំង ការគាំទ្រផ្លូវចិត្ត ជំនួយផ្លូវច្បាប់ ក៏ដូចជាជំនួយគាំទ្រផ្នែកសេដ្ឋកិច្ច ជំនាញ មុខរបរ និងឯកសារសម្រាប់គាំទ្រដល់ការធ្វើសមាហរណកម្មរយៈពេលវែង ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល ក៏បានយកចិត្តទុកដាក់ដល់សិទ្ធិកុមារដែលកុមារ (តាំងពីទារក) គឺជាអ្នកជំនាន់ក្រោយរបស់សង្គម ជាពិសេសសិទ្ធិកុមារក្នុងទេសន្តរប្រវេសន៍ ដែលត្រូវទទួលបានដោយសក្តិសម ។

✓ **កម្មវិធីផ្អែកលើគោលការណ៍មូលដ្ឋាននៃសមភាពយេនឌ័រ**

ទោះបីជាការជួញដូរមនុស្សកើតឡើងចំពោះបុរស និងស្ត្រីក៏ដោយ ក៏ស្ត្រីទទួលរងផលប៉ះពាល់ខុសពីបុរស បើគិតអំពីប្រភេទនៃការជួញដូរ ទម្រង់នៃការរំលោភបំពាន និងផលវិបាកនៃអំពើជួញដូរមនុស្ស។ កត្តាសង្គម អាយុ តួនាទីយេនឌ័រ និងអត្តសញ្ញាណ ក៏រួមចំណែកដល់ការកើនឡើងនៃភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារីចំពោះអំពើជួញដូរមនុស្សផងដែរ ។ ភាពក្រីក្រ ទាក់ទងទៅនឹងយេនឌ័រ ។ កង្វះឱកាសការងារសមរម្យ និងការគ្រប់គ្រងលើធនធានហិរញ្ញវត្ថុ គួបផ្សំនឹងការទទួលបានការអប់រំតិចតួចរបស់ស្ត្រី គឺជាកត្តាដែលនាំឱ្យមានការកើនឡើងនូវចំនួនស្ត្រីដែលស្វែងរកការងារ និងប្រាក់ចំណូល នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការផ្សងព្រេងចេញទៅក្រៅប្រទេស ។ ជារឿយៗ ស្ត្រីបានព្យាយាមចេញទៅដោយគ្មានឯកសារផ្លូវច្បាប់ អាស្រ័យដោយកង្វះពេលវេលា និងថវិកាដែលត្រូវចំណាយខ្ពស់ ។ ម្យ៉ាងទៀត ការងារសម្រាប់ស្ត្រី ភាគច្រើនមានកម្រិតទាប បៀវត្សរ៍តិច និងងាយប្រឈមនឹងភាពរងគ្រោះ ឧទាហរណ៍ ជាអ្នកបម្រើតាមគ្រួសារ កម្មករតាមកសិដ្ឋាន កម្មកររោងចក្រ សហគ្រាស ជាដើម ដែលមិនសូវទាមទារកម្រិតវប្បធម៌ខ្ពស់ ធ្វើឱ្យស្ត្រីខ្វះការយល់ដឹងអំពីបំណិនជីវិត ក្នុងការការពារខ្លួនពីភាពរងគ្រោះដោយការរំលោភបំពាន ការកេងប្រវ័ញ្ច និងអំពើជួញដូរមនុស្ស ។

ការបង្ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស បានយកចិត្តទុកដាក់ជាសំខាន់លើការទទួលស្គាល់អំពីវិសមភាពយេនឌ័រ និងភាពខុសគ្នារវាងស្ត្រីនិងបុរស ទាំងចំណង់ចំណូលចិត្ត បទពិសោធន៍ ទស្សនៈ កម្រិតនៃការទទួលបានការអប់រំ និងទំហំនៃការទទួលខុសត្រូវ ។ ការរើសអើងយេនឌ័រ និងការប្រកួតប្រជែងផ្នែកឧត្តមភាពដើម្បីគ្រប់គ្រងអ្នកដែលទន់ខ្សោយជាងខ្លួន បង្កើតឱ្យមានភាពលម្អៀងក្នុងជីវភាពរស់នៅរវាងបុរស និងស្ត្រី ដែលជាទូទៅ ស្ត្រីគឺជាអ្នកទទួលរងគំនាប ការប្រមាថមាក់ងាយ រំលោភបំពានបន្ទុចបង្អាក់ ដែលមិនអាចមានឱកាសគ្រប់គ្រាន់ក្នុងការទទួលបានសិទ្ធិ ធនធាន និងផលប្រយោជន៍ដែលជារបស់ខ្លួន ។ ហេតុនេះ វិធីសាស្ត្រសម្រាប់ការបង្ការទប់ស្កាត់ភាពរងគ្រោះក្នុងចំណោមស្ត្រី កុមារី និងបុរសមិនដូចគ្នាទេ ។

អំពើហិង្សាលើស្ត្រី និងក្មេងស្រីបានក្លាយជាបរិបទដ៏សំខាន់មួយដែលនាំទៅរកការធ្វើចំណាកស្រុកដោយប្រថុយប្រថានប្រឈមនឹងគ្រោះថ្នាក់ ។ កំណើននៃជនចំណាកស្រុកជាស្ត្រី គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ ព្រោះស្ត្រីគឺជាមេគ្រួសារ ជាអ្នកទទួលបន្ទុកការងារអប់រំកូនចៅ ថែទាំទុកដាក់ទ្រព្យធន និងជាអ្នកបន្តប្រពៃណី វប្បធម៌គ្រួសារ ដែលជាអត្តសញ្ញាណជាតិ ។ លើសពីនេះទៅទៀត ការផ្លាស់ប្តូរផ្នត់គំនិតរបស់មនុស្សក្នុងសង្គម ក្នុងការទទួលខុសត្រូវលើសុវត្ថិភាព និងការអភិវឌ្ឍន៍កុមារក្នុងគ្រួសារ បញ្ហាកុមារ និងទារកក្នុងទេសន្តរប្រវេសន៍ គឺជាបញ្ហាថ្មី ដែលមានផលប៉ះពាល់យូរអង្វែងដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ហួតដល់នយោបាយជាតិ និងអន្តរជាតិ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ ។

### ✓ ការចូលរួមដោយសកម្មពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ

គណៈកម្មាធិការជាតិទទួលស្គាល់ថា អង្គការសង្គមស៊ីវិល នៅតែមានសារៈសំខាន់ អាចជួយបំពេញចន្លោះខ្វះខាត ដើម្បីឱ្យមានភាពប្រសើរឡើង នូវការផ្តល់កិច្ចអន្តរាគមន៍ ជាពិសេស ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះ ក៏ដូចជាការស្វែងរកបទល្មើស ។ អង្គការដៃគូដែលមានជំនាញឯកទេសពាក់ព័ន្ធនៅតែមានតួនាទីធ្វើជាដៃគូក្នុងការគាំទ្រដល់កិច្ចដំណើរការនៃការផ្តន្ទាទោសចំពោះបទល្មើសនានា ជាពិសេសបទល្មើសជួញដូរមនុស្ស ដើម្បីជួយដល់វិស័យយុត្តិធម៌ព្រហ្មទណ្ឌ សេវាច្បាប់ និងការគាំពារផ្នែកចិត្តសាស្ត្រក៏ដូចជាការផ្តល់សេវាបន្តសម្រាប់ការគាំទ្រដល់ជនរងគ្រោះ និងការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៍ ។ ព្រមជាមួយនេះ អ្នកផ្តល់សេវាក្នុងអង្គការដៃគូ ចាំបាច់ត្រូវមានកិច្ចសហការ និងការប្រឹក្សាយោបល់ជាមួយក្រសួងជំនាញពាក់ព័ន្ធ ដើម្បីទទួលបានព័ត៌មាន និងការណែនាំអនុវត្តសកម្មភាពទៅតាមគោលការណ៍ច្បាប់ និងគោលនយោបាយជាតិ ដើម្បីឱ្យជនរងគ្រោះទទួលបានផលប្រយោជន៍ពិតប្រាកដជាអតិបរមា ។

### ✓ កិច្ចសហប្រតិបត្តិការជាពហុវិស័យ និងភាពជាដៃគូ

គណៈកម្មាធិការជាតិ លើកទឹកចិត្តចំពោះកិច្ចសហការ ការសម្របសម្រួល និងភាពជាដៃគូនៅគ្រប់កម្រិត។ ស្ថាប័នក្នុងរាជរដ្ឋាភិបាលនឹងទទួលបានការសម្របសម្រួលពីគណៈកម្មាធិការជាតិ (គ.ជ.ប.ជ) និងបង្កើតភាពជាដៃគូ ជាមួយភាគីពាក់ព័ន្ធចម្រុះ ដូចជា និស្សិត សាស្ត្រាចារ្យឯកទេស/អង្គការសិក្សាស្រាវជ្រាវ ក្រុមតស៊ូមតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសាសនា វិស័យឯកជន ម្ចាស់ជំនួយ សមត្ថកិច្ច និងរដ្ឋាភិបាលនៃប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីឱ្យកិច្ចសហប្រតិបត្តិការ មានដំណើរការល្អបំផុតសម្រាប់ជាយុទ្ធវិធីគ្រប់ជ្រុងជ្រោយពហុវិស័យក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងបួន និងសកម្មភាពនៃផែនការ និងដើម្បីឱ្យមានលទ្ធផលជាផ្លែផ្កាតាមការរំពឹងទុក ។ ផែនការយុទ្ធសាស្ត្រជាតិ គាំទ្រដល់ការបង្កើតយន្តការ ប្រព័ន្ធបញ្ជូន និងទទួលជនរងគ្រោះថ្នាក់ជាតិដែលមានប្រសិទ្ធភាព ដើម្បីពង្រឹងសេវាការពារជនរងគ្រោះដោយអំពើជួញដូរគ្រប់រូបភាព និងកិច្ចការពារជនងាយរងគ្រោះដទៃទៀត បានល្អប្រសើរ ។

ប្រព័ន្ធនេះទាមទារឱ្យមានការត្រួតពិនិត្យ បង្ការការកើតមានឡើងនូវអំពើហិង្សា និងកេងប្រវ័ញ្ចគ្រប់រូបភាពលើជនរងគ្រោះ និងត្រូវផ្តល់កិច្ចការពារដល់ជនងាយរងគ្រោះគ្រប់តំណាក់កាលនៃកិច្ចអន្តរាគមន៍។ មិនតែប៉ុណ្ណោះ ផែនការយុទ្ធសាស្ត្រជាតិ គាំទ្រដល់ការពង្រឹងសមត្ថភាព ការផ្លាស់ប្តូរឥរិយាបទពីភាពព្រងើយកន្តើយ អន់ថយ និងរបៀបរបបការងារដែលមិនមានគុណភាព «*ឱ្យទៅជារបត់ការងារមួយ ដែលឆ្លុះបញ្ចាំងពីសង្គមមួយដែលមានវិន័យ សីលធម៌ល្អ ការគោរព និងការទទួលខុសត្រូវ*»។ អន្តរាគមន៍ជាពហុវិស័យគឺសម្រាប់ការពង្រឹងប្រសិទ្ធភាពនៃសកម្ម ភាពបង្ការ ទប់ស្កាត់បទល្មើសបានទាន់ពេល កាត់បន្ថយភាពរងគ្រោះក្នុងសង្គម ព្រមទាំងគាំទ្រភាពជាដៃគូរវាងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តផែនការប្រកបដោយប្រសិទ្ធភាព ។

### ✓ ការត្រួតពិនិត្យ វាយតម្លៃជាប្រព័ន្ធ និងមាននិរន្តរភាព

ប្រព័ន្ធការងារនេះទាមទារឱ្យមានការត្រួតពិនិត្យ ដើម្បីបង្ការការកើតមានឡើងនូវអំពើហិង្សា និងកេងប្រវ័ញ្ចគ្រប់រូបភាពលើជនរងគ្រោះ និងត្រូវផ្តល់កិច្ចការពារដល់ជនងាយរងគ្រោះគ្រប់ដំណាក់កាលនៃកិច្ចអន្តរាគមន៍។ មិនតែប៉ុណ្ណោះ ផែនការយុទ្ធសាស្ត្រជាតិ គាំទ្រដល់ការពង្រឹងសមត្ថភាព ការផ្លាស់ប្តូរឥរិយាបទពីភាពព្រងើយ

កន្ទើយ អន់ថយ និងរបៀបរបបការងារដែលមិនមានគុណភាព « *ឱ្យទៅជារបត់ការងារមួយ ដែលឆ្លុះបញ្ចាំងពីប្រព័ន្ធសង្គមមួយដែលមានគណនេយ្យភាព វិន័យថ្លៃថ្នូរ សីលធម៌ល្អ ការគោរព និងការទទួលខុសត្រូវ*»។ អន្តរាគមន៍ជាពហុវិស័យ គឺសម្រាប់ការពង្រឹងប្រសិទ្ធភាពនៃសកម្មភាព បង្ការ ទប់ស្កាត់បទល្មើសបានទាន់ពេល កាត់បន្ថយភាពរងគ្រោះក្នុងសង្គមព្រមទាំងគាំទ្រភាពជាដៃគូរវាងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តផែនការប្រកបដោយប្រសិទ្ធភាព ។

ការត្រួតពិនិត្យ និងវាយតម្លៃ គឺជាសមាសធាតុសំខាន់មួយនៃផែនការសកម្មភាពជាតិ។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរឹងមាំមួយនឹងត្រូវបានបង្កើតឡើងដើម្បីកំណត់អំពីបរិមាណ និងគុណភាពនៃការអនុវត្តឆ្លើយតបទៅនឹងភាពចាំបាច់នៃតម្រូវការ ដោយផ្អែកលើសូចនាករសម្រាប់វាស់ស្ទង់ផលប៉ះពាល់ សមិទ្ធផលបទពិសោធន៍ និងមេរៀនល្អៗសម្រាប់គំនិតផ្តួចផ្តើមថ្មី ។

## គ.៥. គោលដៅ និងគោលបំណង

ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ ឆ្នាំ២០១៩-២០២៣ **មានគោលដៅ** *បន្តលើកកម្ពស់រាល់កិច្ចខិតខំប្រឹងប្រែង ក្នុងសង្គម និងរិះរកវិធានការនិងវិធីសាស្ត្រថ្មីៗ ដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់រាល់ទម្រង់ចាស់ ថ្មី នៃអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងរាល់អំពើពាក់ព័ន្ធដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជាទោះជានៅទីណាក៏ដោយ ។*

ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្ស លើកកម្ពស់សាមគ្គីភាព ឯកភាព និងកិច្ចសហការក្នុងភាពជាដៃគូរវាងសហគមន៍ជាតិ និងជាមួយអន្តរជាតិ *ក្នុងគោលបំណង ធានាឱ្យមានប្រព័ន្ធគាំពារសង្គមដើម្បីការបង្ការទប់ស្កាត់ភាពរងគ្រោះឱ្យមានប្រសិទ្ធភាព ការអនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្តន្ទាទោសយ៉ាងសុក្រឹត្យចំពោះបទឧក្រិដ្ឋនេះ ដើម្បីយុត្តិធម៌សង្គម ជាពិសេសការការពារសិទ្ធិ ផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាមនុស្សគ្រប់វ័យ គ្រប់ភេទ និងនៅគ្រប់ស្ថានភាព ។*

## គ.៦. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវទស្សនៈវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ គោលដៅ និងគោលបំណង ដែលកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជំហានទី២ សម្រាប់អនុវត្តក្នុងឆ្នាំ២០១៩-២០២៣ ចាំបាច់ត្រូវបន្តជំរុញអនុវត្តយុទ្ធសាស្ត្រទាំងបួន ដែលបានកំណត់ក្នុងផែនការបន្តបន្ទាប់កន្លងមក និងនៅតែមានសារៈសំខាន់ ក្នុងនោះកុមារ គឺជាស្នូលនៃយុទ្ធសាស្ត្រ ។ យុទ្ធសាស្ត្រទាំងបួនគឺ៖

*១. ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា*

*២. លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ*

*៣. លើកកម្ពស់ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ*

*៤. បង្កើនកិច្ចការពារជនរងគ្រោះ (ជាពិសេសស្ត្រី និងកុមារ) ។*

## យុទ្ធសាស្ត្រទី១ ៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

**ចង្កោមសកម្មភាពចម្បងៗ ៖** សរុបមកមានសកម្មភាពចម្បងៗ ចំនួន ៦៧

| | ៤.១.១១.ជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច សម្រាប់ត្រៀមផ្តល់សេវាក្នុងមណ្ឌលសំចតប៉ោយប៉ែត ដែលគ្រោងសាងសង់ (ក្រោមកិច្ចសហការពីភាគីថៃ) | | -ក្រសួង ស.អ.យ | | | x | x | x | | ថវិកាជាតិ<br>ថវិកាដៃគូ |
| ៤.២. ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែល្អប្រសើរ ដើម្បីឱ្យជនរងគ្រោះជាពិសេសស្ត្រី និងកុមារ ទទួលបានសេវាគាំទ្រ និងថែទាំបានឆាប់រហ័សដល់ដៃ ឆ្លើយតបនឹងតម្រូវការចាំបាច់ | - ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសេវា<br>- ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍<br>- លិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្តល់នីតិសម្បទាដល់ជនរងគ្រោះ ត្រូវបានបង្កើត<br>- សក្តានុពលពង្រីកចំណូលដល់ ពលករ ត្រូវបានរកឃើញ<br>- មូលហេតុធ្វើឲ្យមានចំណាកស្រុកច្រើន ត្រូវបានរកឃើញ | | | | | | | | | |
| | ៤.២.១ រៀបចំគោលការណ៍ណែនាំ ស្តីពីយន្តការបញ្ជូនជនរងគ្រោះ | | -ក្រសួង ស.អ.យ<br>-អង្គការដៃគូពាក់ព័ន្ធ | -ក្រសួង ស.អ.យ<br>-ដៃគូពាក់ព័ន្ធ<br>-វតេនៈអ៊ីនធើណេសិនណល<br>-អង្គការក្តីសង្ឃឹមយុត្តិធម៌<br>-SAF/UNW-ILO | x | x | x | | | -ថវិកាជាតិ<br>-វតេនៈអ៊ីនធើណេសិនណល<br>-ក្តីសង្ឃឹមយុត្តិធម៌<br>-SAF/UNW-ILO |
| | ៤.២.២ ផ្តល់សេវាប្រឹក្សាយោបល់តាមទូរស័ព្ទដល់ពលករទេសន្តរប្រវេសន៍រងគ្រោះដោយអំពើហិង្សា និងការជួញដូរមនុស្ស ហើយបញ្ជូនពួកគាត់ទៅរកសេវាសមស្រប ដោយផ្អែកលើអភិក្រមសិទ្ធិមនុស្ស និងមានលក្ខណៈឆ្លើយតបផ្នែកយេនឌ័រ | | -ក្រសួង ស.អ.យ<br>-ក្រសួងមហាផ្ទៃ<br>-អង្គការដៃគូពាក់ព័ន្ធ | -ក្រសួង ស.អ.យ<br>-ក្រសួងមហាផ្ទៃ<br>-CHC<br>-SAF/UNW-ILO | x | x | x | x | | -ថវិកាជាតិ<br>-CHC<br>-SAF/UNW-ILO |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ៤.២.៣. ពង្រឹងកិច្ចប្រឹងប្រែងដើម្បីអនុវត្តឱ្យបានពេញលេញនូវពិធីសារសម្រាប់ការកំណត់អត្តសញ្ញាណបឋមដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងចំណោមជនងាយរងគ្រោះ និងបណ្តុះបណ្តាលមន្ត្រីអំពីរបៀបផ្តល់សេវានេះ (USA-3) | | -ក្រសួង ស.អ.យ | -ស្ថាប័ន និង ដៃគូពាក់ព័ន្ធ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.៤.ពង្រឹងការផ្តល់សេវាក្នុងមណ្ឌលសំចត និងស្តារនីតិសម្បទា ដើម្បីជួយសម្របសម្រួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស (កោះកុង បាត់ដំបង ស្វាយរៀង បន្ទាយមានជ័យ) | | -ក្រសួង ស.អ.យ | -គ.ឧ.ប.ជ<br>-អង្គការដៃគូ ពាក់ព័ន្ធ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.៥. បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការទទួលបញ្ជូនមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទទៅក្នុងសហគមន៍ | | -ក្រសួង ស.អ.យ<br>-ក្រសួង ក.ប.ទ.ស.អ<br>-ក្រសួង អ.យ.ក<br>-ក្រសួង ក.ប | -អាជ្ញាធរមូលដ្ឋាន<br>-តេនះអ៊ីនធើណេសិនណល<br>-អង្គការដៃគូ ពាក់ព័ន្ធ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ<br>-តេនះអ៊ីនធើណេសិនណល |
| | ៤.២.៦. រៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់នីតិសម្បទាដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះ | | -ក្រសួង ស.អ.យ<br>-ក្រសួង ក.ប.ទ.ស.អ | -អគ្គ គ.ជ.ប.ជ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.៧.រៀបចំបែបបទផ្តល់នីតិសម្បទាដល់មណ្ឌលថែទាំជំនួស របស់អង្គការ | | -ក្រសួង ស.អ.យ<br>-ក្រសួងយុត្តិធម៌ | -មណ្ឌលថែទាំ ជំនួសរបស់ អង្គការដែលត្រូវ ទទួលនីតិ សម្បទា | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ៤.២.៨.បន្តការចុះធ្វើអធិការកិច្ច មជ្ឈមណ្ឌលស្តារនីតិសម្បទារបស់រដ្ឋ និងអង្គការដៃគូ សម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស | | -ក្រសួង ស.អ.យ<br>-គ.ជ.ប.ជ | -នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន គ.រ.ប.ជ/គ.ខ.ប.ជ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.៩. ពិនិត្យឡើងវិញ រៀបចំតាក់តែង និងបញ្ចប់ សេចក្តីព្រាង បែបបទផ្តល់នីតិសម្បទាដល់មណ្ឌល ថែទាំជំនួសរបស់អង្គការ និងអនុវត្ត | | -ក្រសួង ស.អ.យ<br>-ក្រសួងយុត្តិធម៌ | -ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.១០. បង្កើនការទទួលខុសត្រូវរបស់មន្ត្រីស្ថានទូត និងកុងស៊ុល ប្រចាំប្រទេសគោលដៅក្នុងការគ្រប់គ្រង និងដោះស្រាយបញ្ហាពលករ និងប្រជាជនកម្ពុជាដែលរងគ្រោះនៅក្រៅប្រទេស | | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | x | x | x | x | x | -ថវិកាជាតិ |
| | ៤.២.១១. ពង្រឹងកិច្ចប្រឹងប្រែងដើម្បីដាក់បញ្ចូលធាតុចូលពីអង្គការមិនមែនរដ្ឋាភិបាលទៅក្នុងគោលនយោបាយ សម្រាប់ការផ្ទេរសិទ្ធិអាណាព្យាបាលជាផ្លូវការសម្រាប់កុមាររងគ្រោះ ( USA-13 ) | | -គ.ជ.ប.ជ<br>-ក្រុមការងារការពារជនរងគ្រោះ<br>-ក្រសួង ស.អ.យ | | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.១២.សហការជាមួយក្រសួងពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ សិក្សាអំពីសក្តានុពលភូមិសាស្ត្រដើម្បីបង្កើត និងពង្រីកចំណូលដល់ពលករក្រោយពីវិលត្រឡប់ពីក្រៅប្រទេស | | -គ.ជ.ប.ជ<br>-ក្រសួងស.អ.យ | -គ.រ.ប.ជ/ គ.ខ.ប.ជ<br>-ដៃគូពាក់ព័ន្ធ<br>-វេទិកាអ៊ីនធើណេសិនណល | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ៤.២.១៣. សិក្សាកេមូលហេតុដែលនាំឱ្យមានចំណាកស្រុកច្រើន ជាពិសេសចំណាកស្រុកមិនប្រក្រតី និងកំណើនពលករកម្ពុជានៅក្រៅប្រទេស ដោយមិនបានចុះបញ្ជី | | -គ.ជ.ប.ជ<br>-ក្រសួង ក.ប<br>-ស្ថានតំណាងប្រចាំប្រទេសគោលដៅ /ក.ប.ទ.ស.អ<br>-ក្រសួង ស.អ.យ | -គ.រ.ប.ជ/ គ.ខ.ប.ជ<br>-ដៃគូពាក់ព័ន្ធ<br>-វេទិកាអ៊ីនធើណេសិនណល | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ<br>-វេទិកាអ៊ីនធើណេសិនណល |
| | ៤.២.១៤.ពង្រឹងកិច្ចសហការជាមួយស្ថាប័នអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងបណ្តាអង្គការដៃគូ ដើម្បីតាមដានសន្តិសុខនិងសុវត្ថិភាពទារក និងកុមារ ជាជនរងគ្រោះក្រោយពីត្រូវបានបំបែក ឬតាមម្តាយ ដែលដាក់ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន (ករណីពពោះជំនួស និងទារក ឬកុមារដែលមានម្តាយជាប់ឃុំ) | | -តុលាការ/ស្ថាប័នអយ្យការ<br>-គ.ជ.ប.ជ<br>-ក្រសួងស.អ.យ | -អាជ្ញាធរ<br>-សមត្ថកិច្ចមូលដ្ឋាន<br>-AIM, សម្ព័ន្ធអង្គការចាប់ដៃ និងអង្គការដៃគូពាក់ព័ន្ធ | x | x | x | x | x | **ថវិកាជាតិ**<br>**ថវិកាដៃគូ**<br>AIM, សម្ព័ន្ធអង្គការចាប់ដៃ |
| | ៤.២.១៥.ផ្សព្វផ្សាយ និងជំរុញឱ្យប្រើប្រាស់នូវបទដ្ឋានស្តីពីនីតិវិធីប្រតិបត្តិ សម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងកម្ពុជា និងថៃ | | -ក្រសួងស.អ.យ<br>-អង្គការដៃគូពាក់ព័ន្ធ | -សមត្ថកិច្ចពាក់ព័ន្ធ<br>-ខេត្តជាប់ព្រំដែន<br>-វេទិកាអ៊ីនធើណេសិនណល | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ<br>-វេទិកាអ៊ីនធើណេសិនណល |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ៤.២.១៦. ពិនិត្យនិងកែសម្រួលឡើងវិញនូវបទដ្ឋាននីតិវិធីប្រតិបត្តិ សម្រាប់ទទួលនិងបញ្ជូនជនរងគ្រោះ ដោយអំពើជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ឆ្នាំ២០១០) | | -ក្រសួងស.អ.យ<br>-ក្រុមការងារការពារជនរងគ្រោះ | -ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>-អង្គការដៃគូពាក់ព័ន្ធ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.១៧. ពង្រឹងកិច្ចសហការ ជាមួយសាលាដំបូងទាំង ២៥រាជធានី-ខេត្ត ក្នុងដំណើរការរឿងក្តី ករណីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើរំលោភបំពានលើកុមារ.. ដើម្បីតាមដានករណី | | -ក្រសួងស.អ.យ<br>-នគរបាលយុត្តិធម៌<br>-ស្ថាប័នតុលាការ<br>-ស្ថាប័នអយ្យការ | -គ.ជ.ប.ជ<br>-ក្រសួងយុត្តិធម៌<br>-ក្រសួងមហាផ្ទៃ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.១៨. បង្កើនការត្រៀមទុក ធនធានសម្រាប់នគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បីសម្រួលបានកាន់តែល្អការតាមដានត្រួតពិនិត្យជនជាប់ចោទដែលត្រូវបានដោះលែងក្រៅឃុំ ក្រោមការត្រួតពិនិត្យផ្លូវច្បាប់ក្នុងការពន្យាសវនាការ (USA-14) | | -ក្រសួងមហាផ្ទៃ<br>-អគ្គស្នងការដ្ឋាននគរបាលជាតិ<br>-កងរាជអាវុធហត្ថលើផ្ទៃប្រទេស | -ស្នងការដ្ឋានរាជធានី ខេត្ត<br>-កងរាជអាវុធហត្ថ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.១៩. បង្កើនកិច្ចប្រឹងប្រែងជួយផ្តល់ការគាំទ្រថវិកាដល់ការចូលរួមរបស់ជនរងគ្រោះក្នុងនីតិវិធីរឿងក្តីស៊ីវិល និងព្រហ្មទណ្ឌ រួមទាំងផ្តល់ជំនួយ ឧបត្ថម្ភដល់ការអនុញ្ញាតឱ្យធ្វើការផ្តល់កន្លែងស្នាក់នៅបណ្តោះ អាសន្ន ឬផ្តល់ឋានៈជាអន្តោប្រវេសន៍ដែលពាក់ព័ន្ធនឹងជនរងគ្រោះជា | | -ក្រសួង ក.ប.ទ.ស.អ<br>-ស្ថានទូតប្រចាំប្រទេសគោលដៅ<br>-ក្រសួង ស.អ.យ | -គ.រ.ប.ជ/គ.ខ.ប.ជ | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ជនបរទេស ដែលចង់រស់នៅបន្តក្នុងប្រទេសនោះ ក្នុងរយៈពេលនៃនីតិវិធីតុលាការ (USA-7) | | | | | | | | | |
| | ៤.២.២០. បង្កើត និងត្រៀមទុកនូវធនធានសម្រាប់អនុវត្តនីតិវិធីជាប្រព័ន្ធ នៅតាមបណ្តាស្ថាន បេសកកម្មកម្ពុជា សម្រាប់ការជួយដល់ជនរងគ្រោះ កម្ពុជានៅក្រៅប្រទេស រាប់ទាំងប្រទេសដែលគ្មានតំណាងការទូតនៅទីនោះ (USA-9) | | -ក្រសួង ក.ប.ទ.ស.អ<br>-ស្ថានទូតប្រចាំប្រទេសគោលដៅ | | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |
| | ៤.២.២១. ពង្រឹងកិច្ចសម្របសម្រួលទំនាក់ទំនង និងការបញ្ជូនរវាងយន្តការបញ្ជូនថ្នាក់ជាតិ(ផ្នែកជួញដូរមនុស្ស)និងយន្តការបញ្ជូនដែលមានស្រាប់ដទៃទៀត រួមទាំងយន្តការបញ្ជូនជនរងគ្រោះដោយអំពើហិង្សាផង ដើម្បីលើកកម្ពស់ការផ្តល់សេវាដល់ជនរងគ្រោះ | | -គ.ជ.ប.ជ<br>-ក្រុមការងារការពារជនរងគ្រោះ<br>-ក្រសួង ស.អ.យ | | x | x | x | x | x | -ថវិកាជាតិ<br>-ថវិកាដៃគូ |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១

## លិខិតុបករណ៍អន្តរជាតិសហប្រជាជាតិ និងអាស៊ាន

- អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនារីភេទ ដែលកម្ពុជាបានចូលជាសមាជិក ឆ្នាំ១៩៩២ (CEDAW) ។ និងពិធីសារបន្ថែម (Optional Protocol ឆ្នាំ1999)។ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងលើស្ត្រី បានដាក់ចេញអនុសាសន៍ទូទៅលេខ២៦ (ខែធ្នូ ឆ្នាំ២០០៨) ស្តីពីពលករទេសន្តរប្រវេសន៍ជាស្ត្រី ដោយបានកំណត់ពីកាតព្វកិច្ចរបស់ភាគីរដ្ឋាភិបាលក្នុងការគោរព ការការពារ និងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សចំពោះពលករទេសន្តរប្រវេសន៍ជាស្ត្រី។
- ប្រទេសកម្ពុជា គឺជារដ្ឋសមាជិកមួយរបស់អង្គការសហប្រជាជាតិ ក្នុងចំណោមសមាជិកសរុបទាំង១៩៣ ដែលបានអនុម័តគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) ក្នុងឆ្នាំ២០១៥ "ធ្វើឱ្យមានការប្រែក្លាយពិភពលោករបស់យើង៖ របៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០"។ គោលដៅអភិវឌ្ឍន៍ដោយចីរភាព គឺជាការអំពាវនាវជាសកលឱ្យមានការចូលរួមបញ្ចប់ភាពក្រីក្រ ធានាដល់មនុស្សគ្រប់រូបទទួលបានសន្តិភាព វិបុលភាព និងកិច្ចការពារភពផែនដី ។ គោលដៅទាំងនេះមានគោលបំណងសម្រេចឱ្យបាននូវសមភាពយេនឌ័រ សិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា និងការផ្តល់ភាពអង់អាចដល់ស្ត្រីនិងបុរស។ ជារួមបញ្ហាទេសន្តរប្រវេសន៍ការងារ ឬបម្លាស់ទីរបស់ប្រជាពលរដ្ឋ ត្រូវបានលើកឡើងក្នុងគោលដៅចំនួន១១ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំង១៧ ។ ការលុបបំបាត់ពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស ត្រូវបានបញ្ជាក់នៅក្នុងគោលដៅអភិវឌ្ឍន៍ដោយចីរភាព ត្រង់ចំណុចដៅ ៥.២ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃអំពើហឹង្សាលើស្ត្រី និងកុមារីនៅទីសាធារណៈ និងឯកជន ដោយរួមបញ្ចូលទាំងអំពើជួញដូរមនុស្ស និងទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការកេងប្រវ័ញ្ចផ្សេងៗទៀត និងចំណុចដៅ ៨.៧ ស្តីពីការចាត់ វិធានការបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់ពលកម្មដោយបង្ខំ បញ្ចប់នូវទាសភាពសម័យទំនើប និងការជួញដូរមនុស្ស និងធានាការហាមឃាត់ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រួមបញ្ចូលទាំងការជ្រើសរើស និងការប្រើប្រាស់ទាហានជាកុមារ និងបញ្ចប់រាល់ទម្រង់ទាំងអស់នៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។
- ប្រទេសកម្ពុជាជារដ្ឋហត្ថលេខីនៃអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ឆ្នាំ១៩៩០)។

- នៅក្នុងឆ្នាំ២០១៧ ប្រទេសកម្ពុជា បានចុះហត្ថលេខាលើក្របខណ្ឌឯកច្ឆន្ទភាពអាស៊ាន ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ក្នុងគោលបំណងហាមឃាត់ការដកហូតឯកសាររបស់ពលករទេសន្តរប្រវេសន៍ កាត់បន្ថយចំណាយលើថ្លៃសេវាក្នុងការជ្រើសរើស ដែលមានតម្លៃខ្ពស់ហួសហេតុ និងបង្កើនបទប្បញ្ញត្តិលើអ្នកជ្រើសរើសពលករ។
- **«អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពី ការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង»** (ឆ្នាំ២០០០) ត្រូវបានអនុម័ត ដាក់ឱ្យប្រើប្រាស់ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៥ ។
- ច្បាប់ស្តីពី «ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការបង្ការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្សជាពិសេស ស្ត្រីនិងកុមារ» ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ «ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង» ត្រូវបានប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រម លេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០០៦។
- ធម្មនុញ្ញអាស៊ានចូលជាធរមាន នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី ។
- ផែនការសកម្មភាពសាកលរបស់អង្គការសហប្រជាជាតិ ប្រឆាំងការជួញដូរមនុស្ស ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១០ ។
- សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ រាជធានីភ្នំពេញ ។
- សេចក្តីប្រកាសអំពីអនុសញ្ញាអាស៊ាន ស្តីពី «ការប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥» (The ASEAN Convention on Trafficking in Person during the 27th ASEAN SUMMIT in 21st Nov 2015 in Kulalumpur, Malasia) ។
- ការឆ្លើយតបរបស់អាស៊ានចំពោះអំពើជួញដូរមនុស្ស៖ «បញ្ចប់និទណ្ឌភាពសម្រាប់ពួកជួញដូរមនុស្ស និងផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ឆ្នាំ២០០៦ និង២០០៧»។
- សេចក្តីថ្លែងការណ៍រួមអាស៊ាន ស្តីពី កិច្ចការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តរប្រវេសន៍ ប្រកាសក្នុងកិច្ចប្រជុំកំពូលអាស៊ាន នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០០៧ នាទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន (ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers. 12th ASEAN Summit on 13th Jan 2007 in Cebu, Phillipine)
- ផែនការសកម្មភាពអាស៊ាន (សមាសធាតុ TIP) (The 6th ASEAN Summit in Hanoi, 15-16th Dec 1998 អាស៊ាន មាន Plan of Action ស្តីអំពី Trannational Crime ហើយមានកំណត់នូវការងារសហប្រតិបត្តិការលើការប្រឆាំងការជួញដូរមនុស្សដែលមានស្ត្រី និងកុមារ ។ ឆ្នាំ២០០៤ ទើបមាន Plan of Action មួយទៀត និយាយពី ASEAN Security Community និង ២០១២ មាន Action Plan to Combat Transnational Crime)

- សេចក្តីប្រកាសអាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនៅក្នុងតំបន់អាស៊ាន (២០០៤)
- ផែនការសកម្មភាពថ្នាក់តំបន់របស់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) 6th Dec 1995
- អនុសញ្ញាស្តីពីការលុបបំបាត់ទម្រង់ដ៏ធ្ងន់ធ្ងរបំផុតនៃការរើសអើងប្រឆាំងនឹងស្ត្រីឆ្នាំ១៩៧៩ (The Convention on the Elimination of All Forms of Discrimination against Women (CEDAW), adopted in 1979 by the UN General Assembly, is often described as an international bill of rights for women.)។

## ឧបសម្ព័ន្ធ ២

## លិខិតុបករណ៍សម្រាប់ទ្វេភាគី ពហុភាគី

- ផែនការសកម្មភាព ក្នុងមហាអនុតំបន់មេគង្គ ( COMMIT SPA 4 )
- «អនុសញ្ញាអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ចុះហត្ថលេខា ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ និងផែនការសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរបស់អាស៊ាន។
- សេចក្តីថ្លែងការណ៍រួម ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៧ របស់ដំណើរការបាលី ស្តីពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៨ (Declaration of the Seventh Ministerial Conference of the BALI PROCESS on People Smuggling, Trafficking in Persons and Related Transnational Crime , on 7th August 2018 )។
- កតិកាសញ្ញាពិភពលោក ស្តីពី «ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» ដែលបានអនុម័ត ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេស ម៉ារ៉ុក ។
- អនុស្សរណៈ និងកិច្ចព្រមព្រៀង ទ្វេភាគី ពហុភាគី ស្តីពីកិច្ចសហប្រតិបត្តិការ បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស រវាងប្រទេសពាក់ព័ន្ធជាមួយព្រះរាជាណាចក្រកម្ពុជាមានជាអាទិ៍៖
  - «អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ» (ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ ) ។
  - កិច្ចព្រមព្រៀងរវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការការងារបង្ការ និងប្រឆាំងបទល្មើស (ភ្នំពេញ ១៦ មិនា ១៩៩៧)។
  - អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃ «ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ» (ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៣ និងបានធ្វើវិសោធនកម្មហើយចុះហត្ថលេខាជាថ្មី នៅថ្ងៃទី៣០ ខែតុលា ក្នុងឆ្នាំ២០១៤ ដោយក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គមកិច្ច និងសន្តិសុខមនុស្សថៃ ) ។

- កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម «ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះដោយអំពើជួញដូរ» (ដែលចុះហត្ថលេខា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ និងធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២)។
- គោលការណ៍ព្រមព្រៀង «ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម» (ដែលចុះហត្ថលេខាដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃកម្ពុជា និងនាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើសសណ្តាប់ធ្នាប់សង្គម នៃក្រសួងនគរបាលវៀតណាម នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧)។
- កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម «ស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញដូរ» (ដែលត្រូវបានចុះហត្ថលេខាដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩)។
- កិច្ចព្រមព្រៀងទ្វេភាគី រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពី «ការពង្រឹងកិច្ចសហការសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដោយលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងអនុរដ្ឋមន្ត្រីក្រសួងការបរទេសចិន ។
- អនុស្សរណៈទ្វេភាគី រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា «ស្តីពី កិច្ចសហប្រតិបត្តិការ សម្រាប់ការបង្ការទប់ស្កាត់ ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ការសង្គ្រោះ ការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរ» ចុះហត្ថលេខា នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ នៅក្រុងញូដេលី សាធារណរដ្ឋឥណ្ឌា លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងអនុរដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា ។

## ឧបសម្ព័ន្ធ ៣

### *បញ្ហាប្រឈម និងចំណុចខ្វះចន្លោះដែលនៅសេសសល់៖*

ក្នុងការវាយតម្លៃពាក់កណ្ដាលអណត្តិនៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ដោយអ្នកវាយតម្លៃឯករាជ្យ ដោយមានកិច្ចសហការពីអង្គការវិនរ៉ក់អន្តរជាតិ បានរកឃើញនូវចំណុចខ្វះចន្លោះ និងភាពប្រឈមមួយចំនួន ដូចខាងក្រោម៖

**ក្នុងយុទ្ធសាស្ត្រទី១ *៖ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា***

- ខ្វះវិធានការដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកឆ្លងដែនតាមច្រករបៀង (មិនផ្លូវការ) និងការចូលទៅធ្វើការងារតាមរដូវកាល ។
- ខ្វះការតាមដានវាយតម្លៃ ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀង ទ្វេភាគី ពហុភាគី ។
- ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី និងខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) មួយចំនួន មិនទាន់មានផែនការសកម្មភាពផ្ទាល់សម្រាប់អនុវត្តនៅឡើយ ។
- របាយការណ៍របស់ក្រសួង ស្ថាប័នជាសមាជិកក៏ដូចជារាជធានី ខេត្ត ខ្វះសូចនាករតាមយុទ្ធសាស្ត្រដែលបញ្ជាក់ពីភាពជាក់លាក់នៃកិច្ចសហការ និងលទ្ធផលក្នុងសកម្មភាពប្រឆាំងការជួញដូរមនុស្ស ។
- របាយការណ៍មានតែតាមក្រសួង មន្ទីរ អង្គភាពខ្លះ តែមិនប្រមូលផ្តុំជារបាយការណ៍របស់ក្រុមការងារអន្តរវិស័យ និងយឺតយ៉ាវសម្រាប់ ការបូកសរុប ។
- ខ្វះយន្តការ និងឧបករណ៍សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ ផែនការ សកម្មភាពតាមបណ្តាថ្នាក់ និងតាមដានប្រសិទ្ធភាពនៃកិច្ចសហ ប្រតិបត្តិការ ។
- ត្រូវការទម្រង់សាមញ្ញនៃរបាយការណ៍មួយឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ និងសូចនាករដែលមានលក្ខណៈជាប្រព័ន្ធ និងអាចវាយតម្លៃបាន ។
- ខ្វះយន្តការ និងផែនការសម្រាប់ការអភិវឌ្ឍសមត្ថភាពមន្ត្រីតាមអង្គភាព ស្ថាប័នដែលជាអ្នកទទួលបន្ទុកអនុវត្ត ។
- ការអនុវត្តគោលនយោបាយនៅមានកម្រិតនៅឡើយដោយសារសមត្ថភាព និងធនធាន ។

**ក្នុងយុទ្ធសាស្ត្រទី២ *៖ ការងារបង្ការទប់ស្កាត់***

- មិនទាន់មានយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ ដែលមានស្តង់ដាររួម រវាងប្រទេសបញ្ជូន និងប្រទេសទទួល ឱ្យមានលក្ខណៈជាប្រព័ន្ធនៅឡើយ ។

- មិនមានផែនការបញ្ជ្រាបការយល់ដឹងអំពីការជួញដូរមនុស្សនៅតាមកន្លែងបណ្តុះបណ្តាលជំនាញ និងសកម្មភាពជាមួយក្រុមងាយរងគ្រោះតាមសហគមន៍ ដើម្បីបង្ការ ទប់ស្កាត់ភាពរងគ្រោះ ដោយការជួញដូរពលកម្ម ជួញដូរផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃអំពើជួញដូរមនុស្ស ។
- មិនទាន់មានការវាយតម្លៃអំពីគុណភាពនៃកម្មវិធីបណ្តុះបណ្តាល មុនចេញដំណើរ តាមបណ្តាទីភ្នាក់ងារជ្រើសរើសពលករ ។
- ខ្វះការស្រាវជ្រាវអំពីផលប៉ះពាល់នៃការផ្តល់ប្រាក់កម្ចី ការផ្ទេរប្រាក់តាមប្រព័ន្ធផ្លូវការនិងមិនផ្លូវការ និងតុល្យភាពនៃចំណូលនិងចំណាយរបស់ពលករ ដើម្បីមានមូលដ្ឋានក្នុងការរៀបចំគោលនយោបាយកែលម្អប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់បញ្ញើដែល ផ្តល់ប្រយោជន៍ដល់ជនចំណាកស្រុក ក្រុមគ្រួសារ និងសហគមន៍ ។
- មិនទាន់បានបញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងផែនការលើកកម្ពស់សុវត្ថិភាពកុមារ តាមវិស័យក្នុងផែនការសកម្មភាពនៃរាជធានីនិងខេត្ត ។
- មានកុមារជាច្រើនដែលធ្វើទេសន្តរប្រវេសន៍ទៅជាមួយនឹងឪពុកម្តាយរបស់ពួកគេទៅក្រៅប្រទេស ហើយកុមារមួយចំនួនបានកើតនៅទីនោះ។ កុមារមិនមានសំបុត្រកំណើតនិងមិនបានចូលរៀន ឬបានចូលរៀន ប៉ុន្តែរៀនជាភាសាជាតិរបស់ប្រទេសគោលដៅ ។

***ក្នុងយុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងការជួញដូរមនុស្ស***

- ខ្វះការប្រៀបធៀបទិន្នន័យលទ្ធផលនៃការផ្តន្ទាទោស និងករណីដែលបានបង្ក្រាបក្នុងឆ្នាំ ។
- មុខសញ្ញាមួយចំនួន មិនបានបន្តស៊ើបអង្កេត ឬបង្ក្រាបដោយមូលហេតុមិនបានត្រៀមផែនការថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពប្រឆាំងការជួញដូរមនុស្ស ជាពិសេសក្នុងប្រតិបត្តិការស៊ើបអង្កេត និងបង្ក្រាប ។
- ខ្វះធនធានមនុស្សសម្រាប់កិច្ចការយុត្តិធម៌ ក្នុងការបង្កើតអាជ្ញាធរកណ្តាល និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ក្នុងក្រសួងយុត្តិធម៌ ។
- មិនមានការចងក្រងបទពិសោធន៍ ក្នុងការងារយុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីការសម្រេចចិត្តរបស់តុលាការលើករណីជួញដូរមនុស្ស ។
- មិនមានសូចនាករ សម្រាប់ជាលទ្ធផលនៃការផ្តន្ទាទោស ។
- មិនទាន់បានអនុវត្តប្រព័ន្ធអាជ្ញាធរកណ្តាលសម្រាប់រឿងក្តីឆ្លងដែន ។
- មិនទាន់មានយន្តការពន្លឿននីតិវិធីតុលាការដែលពាក់ពន្ធ័នឹងជនរងគ្រោះជាអនីតិជន

- ក្របខ័ណ្ឌច្បាប់ខុសគ្នារវាងប្រទេសប្រភព និងប្រទេសគោលដៅក៏ជាឧបសគ្គផងដែរ ស្រាប់ការងារផ្តន្ទាទោសជនល្មើស។
- ការផ្តន្ទាទោសជនល្មើសឆ្លងដែនជាបញ្ហាប្រឈមមួយ ហេតុផលមួយគឺជនរងគ្រោះមិនសហការដោយសារដំណើរការចំណាយពេលវេលាយូរ។

*ក្នុងយុទ្ធសាស្ត្រទី៤៖ កិច្ចការពារជនរងគ្រោះ*

- ខ្វះបុគ្គលិកសង្គមកិច្ច និងថវិកា ដើម្បីធ្វើសកម្មភាពជាគម្រូក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងមណ្ឌលរបស់រដ្ឋាភិបាល សម្រាប់ការផ្តល់សេវាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- មិនទាន់បានផ្តល់នីតិសម្បទាដល់មណ្ឌលដែលទទួលថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាល ។
- ការតាមដានជនរងគ្រោះដែលត្រូវបានបញ្ជូនទៅសហគមន៍វិញនៅមានកម្រិត ។
- ជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចខ្លះ មិនទទួលបានសេវាសមស្របនៅឡើយ ។
- ការសម្របសម្រួលការផ្តល់សេវានៅមិនទាន់មានភាពរលូននៅឡើយ ។
- សមត្ថភាពរបស់មន្ត្រីខ្លះលើប្រធានបទមួយចំនួនដូចជា ចិត្តសាស្ត្រសម្ភាសន៍ជនរងគ្រោះ និងតាមដានវាយតម្លៃនៅមានកម្រិត ។
- មិនទាន់មានផែនការតាមដាន និងវាយតម្លៃការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយដល់ជនរងគ្រោះនៃការជួញដូរមនុស្ស ។
- ទិន្នន័យនៃរបាយការណ៍ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនមានការប្រមូលផ្តុំ នៅមានកម្រឹត និងមិនមានសូចនាករច្បាស់លាស់ ។
- មិនទាន់មានច្បាប់ការពារកុមាររងគ្រោះ និងសាក្សី ។
- មិនទាន់មានការអនុវត្តតាមបែបកុមារមេត្រីជាលក្ខណៈស្តង់ដា ក្នុងពេលដំណើរការស៊ើបអង្កេត និងផ្តន្ទាទោស ។
- មិនទាន់មានការបណ្តុះបណ្តាលអ្នកបកប្រែសម្រាប់ធ្វើការងារជាមួយនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

# ឧបសម្ព័ន្ធ ៤
# របបសេវាសន្តិសុខសង្គម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ច្បាប់
### ស្តីពី
### របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## LAW
### ON
### SOCIAL SECURITY SCHEMES FOR PERSONS DEFINED BY THE PROVISIONS OF THE LABOUR LAW

## មាតិការឿង


| | | |
|---|---|---|
| ជំពូកទី ១ | បទប្បញ្ញត្តិទូទៅ | ២ |
| ជំពូកទី ២ | ផ្នែកប្រាក់សោធន | ៥ |
| ជំពូកទី ៣ | ផ្នែកហានិភ័យការងារ | ៧ |
| ជំពូកទី ៤ | បទប្បញ្ញត្តិផ្សេងៗ | ១៣ |
| ជំពូកទី ៥ | ទោសប្បញ្ញត្តិ | ១៦ |
| ជំពូកទី ៦ | អវសានប្បញ្ញត្តិ | ១៩ |


ព្រះរាជក្រម

នស/ រកម/ ០៩០២ / ០១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករនរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

### ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ ។

១

## ឧបសម្ព័ន្ធ ៥
## ទិសដៅសកម្មភាពរបស់គណៈកម្មាធិការជាតិ សម្រាប់ឆ្នាំ២០១៩

១. បន្តពង្រឹងកិច្ចសហការឱ្យបានទូលំទូលាយ ទាំងក្នុងក្របខណ្ឌជាតិ និងជាមួយបណ្ដាប្រទេសពាក់ព័ន្ធជាអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ការពារ និងបង្ក្រាប ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួល ។

៣. ត្រៀមកិច្ចប្រជុំទ្វេភាគី «កម្ពុជា-ចិន» លើកទី៣ ស្ដីពីការអនុវត្តកិច្ចព្រមព្រៀង ស្ដីពីកិច្ចសហការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៤. ត្រៀមកិច្ចប្រជុំទ្វេភាគី លើកទី១ ស្ដីពីការអនុវត្តអនុស្សរណៈ កម្ពុជា-ឥណ្ឌា ប្រឆាំងការជួញដូរមនុស្ស ។

៥. ជំរុញ និងតាមដានការកសាងអនុស្សរណៈ ឬកិច្ចព្រមព្រៀង ស្ដីពីកិច្ចការពារសុវត្ថិភាពពលករ ក្នុងវិស័យនេសាទសមុទ្រ ។

៦. ពង្រឹងកិច្ចសហការជាមួយក្រសួងស្ថាប័ន អង្គការដៃគូជាតិ និងអន្តរជាតិ ជំរុញអនុវត្តកតិកាសញ្ញាពិភពលោកស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលបានអនុម័ត នៅខែធ្នូ ឆ្នាំ២០១៨ ។

៧. សហការជាមួយអង្គការដៃគូ សិក្សាស្រាវជ្រាវលើសេវាកម្មនានាដែលផ្ដល់ជូនពលករ និងការស្រាវជ្រាវ ដទៃទៀតដែលចាំបាច់ ។

៨. ពង្រឹង និងពង្រីកកិច្ចសហការកាន់តែទូលំទូលាយ ឈានទៅដោះស្រាយភាពងាយរងគ្រោះរបស់កុមារគ្រប់រូបភាព រួមទាំងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ។

៩. ពង្រឹងការអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម អំពើជួញដូរផ្លូវភេទ ការជក់ហូតសរីរាង្គ អំពើជួញដូរទារក និងកុមារឆ្លងដែន អំពើពពោះជំនួស អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

១០. ជំរុញការកសាងច្បាប់ (ច្បាប់ស្ដីពី អំពើពពោះជំនួស) និងវិសោធនកម្មច្បាប់ (ក្រមព្រហ្មទណ្ឌ) ឆ្លើយតបទៅនឹងសេចក្ដីត្រូវការចាំបាច់ ។

១១. សម្រេចបញ្ចប់លើសេចក្ដីព្រាង និងប្រកាសដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩- ២០២៣) របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១២. ចុះពិនិត្យស្ថានភាពប្រែប្រួល និងចំណុចសេសសល់ លើការងារលើកកម្ពស់សុវត្ថិភាពពលករនៅក្រៅប្រទេស ដើម្បីមានវិធានការ ។

១៣. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែកដល់មន្ត្រីជំនាញ និងពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារនិងលេខាធិការដ្ឋានរាជធានី-ខេត្ត ។

១៤. បន្តពង្រឹងការងារបង្ការ ទប់ស្កាត់ តាមរយៈការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាពនិងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស ព្រមទាំងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន ក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។

១៥. បញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងកម្មវិធីបង្ការទប់ស្កាត់ ព្រមទាំងកម្មវិធីពង្រឹងភាពអង់អាចដល់ស្ត្រីតាមរយៈការជួយរកការងារឱ្យធ្វើ និងបង្កើតមុខរបរ ។

១៦. រៀបចំវេទិកាអន្តរសាសនា លើកទី៣ ប្រឆាំងអំពើជួញដូរមនុស្ស ។

១៧. រៀបចំទិវាជាតិ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី១៣ នៅថ្នាក់ជាតិ និងនៅទូទាំងប្រទេស ។

១៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ដើម្បីបំផុសប្រជាពលរដ្ឋ ឱ្យយល់ដឹង និងមានវិធានការ បង្ការ ទប់ស្កាត់ និងការពារខ្លួន ពីអំពើជួញដូរមនុស្ស អំពើជួញដូរកុមារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាព ។

១៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

២០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ ។

២១. បន្តរៀបចំវិធានការ «គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី» និងការរៀបចំយន្តការទទួលពលករនៅមណ្ឌលទទួលពលករប៉ោយប៉ែត និងត្រៀមរៀបចំបន្តតាមគោលដៅច្រកទ្វារសំខាន់ៗដទៃទៀត (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ) ។

២២. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី និងជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្របដល់មន្ត្រីអនុវត្តន៍នៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងមន្ត្រីស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងតាមដានការអនុវត្ត ។

២៣. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

២៤. បន្តចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ ជាមួយបណ្តាប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិ ពាក់ព័ន្ធនឹងវិធានការឆ្លើយតបអំពើជួញដូរមនុស្ស ព្រមទាំងសុវត្ថិភាពមនុស្ស ក្នុងទេសន្តរប្រវេសន៍ ។

## ឧបសម្ព័ន្ធ ៦

## អនុសាសន៍សហរដ្ឋអាមេរិក សម្រាប់ឆ្នាំ២០១៩

១. ដោយគោរពតាមនីតិវិធីធ្វើការស៊ើបអង្កេត ចោទប្រកាន់និងផ្តន្ទាទោសយ៉ាងខ្ជាប់ខ្ជួនលើជនល្មើសជួញដូរមនុស្ស និងដាក់ទណ្ឌកម្មឱ្យបានគ្រប់គ្រាន់ដល់ជនជួញដូរពលកម្ម និងផ្លូវភេទ រួមទាំងមន្ត្រីដែលឃុបឃិត ដោយមានដីកាសម្រេចឱ្យជាប់ពន្ធនាគារ ។

២. អនុញ្ញាតិឱ្យប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ សម្រាប់ប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ។

៣. ពង្រឹងកិច្ចប្រឹងប្រែងដើម្បីអនុវត្តឱ្យបានពេញលេញនូវពិធីសារសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះបឋម ក្នុងចំណោមជនងាយរងគ្រោះ និងបណ្តុះបណ្តាលមន្ត្រី អំពីរបៀបផ្តល់សេវានេះ។

៤. បង្កើនការធ្វើអធិការកិច្ចការងារក្នុងប្រភេទការងារដែលងាយរងគ្រោះខ្លាំង ជាពិសេសក្នុងឧស្សាហកម្មឡឥដ្ឋ នេសាទ និងដាំដុះដោយផ្តោតលើការកំណត់រកការជាប់បំណុល ។

៥. បង្កើនលទ្ធភាពក្នុងសេវាសម្រាប់ជនរងគ្រោះ ជាពិសេសបុរស និងក្មេងប្រុស ដែលត្រូវបានគេកេងប្រវ័ញ្ច ឧស្សាហកម្មនេសាទ ។

៦. បង្កើនការធ្វើអធិការកិច្ច និងត្រួតពិនិត្យស្ថាប័នផ្តល់កម្ចី រួមទាំងអង្គការមីក្រូហិរញ្ញវត្ថុឯកជន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ដោយសារបំណុល ដោយបង្ខំក្នុងចំណោមសហគមន៍ដែលមានសេដ្ឋកិច្ចខ្សត់ខ្សោយ ។

៧. បង្កើនកិច្ចប្រឹងប្រែងជួយផ្តល់ការគាំទ្រថវិកាដល់ការចូលរួមរបស់ជនរងគ្រោះក្នុងនីតិវិធីរឿងក្តីស៊ីវិល និងព្រហ្មទណ្ឌ រួមទាំងផ្តល់ជំនួយឧបត្ថម្ភដល់ការអនុញ្ញាតឱ្យធ្វើការ ការផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ឬផ្តល់ឋានៈជាអន្តោប្រវេសន៍ដែលពាក់ព័ន្ធនឹងជនរងគ្រោះជាជនបរទេស ដែលចង់រស់នៅបន្តក្នុងប្រទេសនោះ ក្នុងរយៈពេលនៃនីតិវិធីតុលាការ ។

៨. កែលម្អច្បាប់ ដើម្បីអនុញ្ញាតឱ្យមានសំណងបដិទានក្នុងពេលផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ហើយបង្កើត និងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធអំពីនីតិវិធីប្រតិបត្តិតាមស្តង់ដា សម្រាប់ការគណនា និងការផ្តល់សំណងបដិទាន ។

៩. បង្កើតនិងត្រៀមទុកនូវធនធានសម្រាប់អនុវត្តនីតិវិធីជាប្រព័ន្ធនៅតាមបណ្តាស្ថានបេសកកម្មកម្ពុជា សម្រាប់ការជួយដល់ជនរងគ្រោះកម្ពុជានៅក្រៅប្រទេស រាប់ទាំងប្រទេស ដែលគ្មានតំណាងការទូតនៅទីនោះ ។

១០. ពង្រឹងកិច្ចប្រឹងប្រែងក្នុងការធ្វើអធិការកិច្ចទីភ្នាក់ជ្រើសរើសឯកជន និងបណ្តាញអ្នកទទួលជ្រើសរើសបន្តសម្រាប់ការជ្រើសរើសដោយកេងបន្លំ បោកប្រាស់ និងតាមរបៀបជួញដូរដទៃទៀត ។

១១. បង្កើនការយល់ដឹងជាសាធារណៈ ស្តីពី នីតិវិធីចុះបញ្ជីឯកសារធ្វើដំណើរដែលត្រឹមត្រូវ ដើម្បីសម្រួលឱ្យការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងស្របច្បាប់ ។

១២. អនុវត្តប្រព័ន្ធសម្រាប់ការតាមដាន ប្រមូលចងក្រងនិងរាយការណ៍ទិន្នន័យ ស្តីពីការចោទប្រកាន់ប្រឆាំងការជួញដូរមនុស្ស កិច្ចប្រឹងប្រែងការពារជនរងគ្រោះ ការចែករំលែកព័ត៌មាន ទៅក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ក្នុងរបៀបដែលអាចការពារបានអត្តសញ្ញាណ និងឯកជនភាពជនរងគ្រោះ ។

១៣. ពង្រឹងកិច្ចប្រឹងប្រែងដើម្បីដាក់បញ្ចូលធាតុចូលពីអង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងគោលនយោបាយសម្រាប់ការផ្ទេរសិទ្ធិអាណាព្យាបាលជាផ្លូវការសម្រាប់កុមាររងគ្រោះ ។

១៤. បង្កើនការត្រៀមទុកធនធានសម្រាប់នគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បីសម្រួលបានកាន់តែល្អការតាមដានត្រួតពិនិត្យជនជាប់ចោទដែលត្រូវបានដោះលែងក្រៅឃុំ ក្រោមការត្រួតពិនិត្យផ្លូវច្បាប់ក្នុងការពន្យាសវនាការ ។

## ឧបសម្ព័ន្ធ ៧

## សកម្មភាពដែលប្រទេសសមាជិកអាស៊ាន គប្បីជំរុញអនុវត្តៈ

### ក.ការបង្ការ-ទប់ស្កាត់

១. លើកកម្ពស់ការយល់ដឹង តាមរយៈការអប់រំមនុស្សគ្រប់ស្រទាប់ក្នុងសង្គមឱ្យយល់ដឹង និងចូលរួមបង្ការ ទប់ស្កាត់ មានការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយ NGOs ផ្នែកឯកជន ស្តីពីអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម ទម្រង់ពលកម្មដោយបង្ខំ និងចូលរួមបង្ការទប់ស្កាត់ ការពារ ជាពិសេសដល់ក្រុមជនដែលមានហានិភ័យខ្ពស់ ។

២. កសាង និងពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ មន្ត្រីអន្តោប្រវេសន៍ មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច មន្ត្រីការងារ និងមន្ត្រីពាក់ព័ន្ធទាំងឡាយ ដោយផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស សិទ្ធិកុមារ និងយេនឌ័រ តាមស្ថានភាពជាក់ស្តែង ដោយជំរុញលើកទឹកចិត្តដល់កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធ ។

៣. បង្កើតយន្តការដែលមានប្រសិទ្ធភាព ដើម្បីបង្ការ ទប់ស្កាត់បម្លាស់ទីរបស់ពួកជួញដូរនិងជនរងគ្រោះតាមរយៈការត្រួតពិនិត្យព្រំដែន ការចេញឯកសារអត្តសញ្ញាណ ឯកសារធ្វើដំណើរ បង្ការទប់ស្កាត់ការក្លែងបន្លំ ការក្លែងក្លាយឬប្រើឯកសារអត្តសញ្ញាណ និងឯកសារទុច្ចរិត ។

៤. បង្កើនកិច្ចសហការក្នុងការពិនិត្យ និងពង្រឹងការគ្រប់គ្រងពលករ ទេសន្តរប្រវេសន៍ឆ្លងដែន ចែករំលែកព័ត៌មាន (សម្ងាត់ ឬចំហ) រវាងសមត្ថកិច្ច និងប្រទេសពាក់ព័ន្ធ សំដៅបង្ក្រាប ទប់ស្កាត់ បន្ទុចបង្អាក់ប្រតិបត្តិការរបស់ពួកបណ្តាញ និងជនជួញដូរ ។

៥. អនុវត្តច្បាប់ការងារ តាមរយៈយន្តការដែលសមស្របនឹងបណ្តាយន្តការផ្សេងទៀតដើម្បីលើកស្ទួយ ការពារផលប្រយោជន៍ពលករ កាត់បន្ថយហានិភ័យ ។

៦. សម្របសម្រួលបង្កើត និងជំរុញអនុវត្តផែនការសកម្មភាពជាតិ ជំរុញការអនុវត្ត ដោយផ្តល់អាទិភាពលើសកម្មភាពជាគន្លឹះ ផ្អែកលើគោលនយោបាយ កម្មវិធីសំខាន់ៗ ដែលលើកក្នុងផែនការ និងតាមដានការអនុវត្តឱ្យមានប្រសិទ្ធភាព ។

៧. គាំទ្រការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទពាក់ព័ន្ធ (អាស៊ាន) ប្រមូលទិន្នន័យ វិភាគ ចរិតលក្ខណៈ វិសាលភាព ថ្នាក់ជាតិ តំបន់ ។

៨. កសាងមូលដ្ឋានទិន្នន័យ ដោយប្រមូលចងក្រងទិន្នន័យថ្នាក់ជាតិ មានវិធីសាស្ត្រផ្លាស់ប្តូរទិន្នន័យ (រវាងប្រទេសក្នុងអាស៊ាន) ឈានទៅបង្កើតទិន្នដ្ឋានអាស៊ាន ។

៩. ប្រើប្រាស់និងពង្រឹងការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ ដែលកំណត់អត្តសញ្ញាណនិងជួយជនរងគ្រោះដោយមិនរើសអើង រកឃើញកត្តាមូលហេតុទិដ្ឋភាពនៃភាពរងគ្រោះ អ្នកបង្ក ដើម្បីបង្ការទប់ស្កាត់ កាត់បន្ថយនិងឆ្លើយតបឱ្យបានជាអតិបរមា ។

១០. គាំទ្រសកម្មភាពបង្ការទប់ស្កាត់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ផ្តោតលើការទប់ស្កាត់ ទាំងតម្រូវការ ការផ្គត់ផ្គង់ ដែលជំរុញឱ្យមានអំពើជួញដូរមនុស្ស និងការផ្លាស់ប្តូរឥរិយាបទដែលនាំឱ្យមានភាពរងគ្រោះ ។

១១. រិះរកយុទ្ធសាស្ត្រនិងយុទ្ធវិធីទប់ស្កាត់ និងលុបបំបាត់ការជួញដូរមនុស្សឆ្លងដែនប្រកបដោយកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសប្រភព និងប្រទេសគោលដៅ ។

១២. ពង្រឹងវិធានការបង្ការ ទប់ស្កាត់តម្រូវការរបស់ជនល្មើសនៃរាល់ទម្រង់កេងប្រវ័ញ្ច និងការធ្វើអាជីវកម្មលើមនុស្ស ការពារជនរងគ្រោះ ដើម្បីកុំឱ្យរងគ្រោះម្តងហើយម្តងទៀត ។

១៣. បញ្ចូលប្រធានបទពាក់ពន្ធ័នឹងការជួញដូរ និងអំពើរំលោភបំពានផ្លូវភេទលើកុមារ ក្នុងការផ្សព្វផ្សាយ និងយុទ្ធនាការប្រឆាំងអំពើជួញដូរមនុស្ស ។

១៤. បញ្ចូលបញ្ហាអំពើហិង្សាលើពលករទេសន្តប្រវេសន៍ ជាពិសេសអំពើហឹង្សាយលើពលករទេសន្តប្រវេសន៍ជាស្ត្រី ។

## ខ. កិច្ចការពារជនរងគ្រោះ

១. លើកកម្ពស់ការគោរព និងការពារសិទ្ធិមនុស្សជាពិសេសសិទ្ធិជនរងគ្រោះដោយបំពេញបន្ថែមនូវវិធានការដ៏មានប្រសិទ្ធភាពក្នុងការការពារនិងជួយជនរងគ្រោះ ។

២. ផ្តល់ការថែទាំ គាំទ្រ និងអភិវឌ្ឍដល់ជនរងគ្រោះគ្រប់ភេទ គ្រប់វ័យ ។

៣. កំណត់អត្តសញ្ញាណ (តាមអនុសញ្ញាអាស៊ាន) កសាងនិងអនុវត្តលិខិតុបករណ៍ជាតិ អន្តរជាតិពាក់ព័ន្ធ ដើម្បីឱ្យជនរងគ្រោះទទួលបានទទួលសេវាសុខភាព សេវាបង្ការ ការព្យាបាល ការថែទាំ និងព្យាបាលជំងឺ (ពិសេសជំងឺឆ្លង) សិក្សាហេតុផល និងការប៉ះពាល់រយៈពេលវែង ។

៤. អនុលោមតាមច្បាប់នូវរាល់បទបញ្ញត្តិ បទបញ្ជា និងបណ្តាគោលនយោបាយផ្ទៃក្នុង និងផ្អែកតាមករណីសមស្របនានា (*មិនដាក់ឱ្យជនរងគ្រោះទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ឬរដ្ឋបាលដោយសារតែអំពើខុសច្បាប់ ដែលពួកគេបានប្រព្រឹត្តក្នុងអំឡុងពេលដែលរងគ្រោះដោយអំពើជួញដូរមនុស្សឡើយ*)។

៥. ផ្តល់លទ្ធភាព ជួយឧបត្ថម្ភ ផ្តល់សេវាកម្មនានាដល់កុមារ ស្ត្រីសម្រាប់ស្តារឡើងវិញផ្នែករាងកាយ ចិត្តសាស្ត្រសង្គម និងស្តារនីតិសម្បទា ដោយសហការជាមួយផ្នែកពាក់ព័ន្ធបង្កើតបណ្តាញផ្តល់សេវា ផ្តល់ការថែទាំវេជ្ជសាស្ត្រ ការពិគ្រោះយោបល់ ការអប់រំ ឱកាសបណ្តុះបណ្តាល ជំនួយផ្នែកច្បាប់ និងសេវាបកប្រែជាដើម ។

៦. ប្រើប្រាស់ប្រព័ន្ធ៖ កសាងប្រព័ន្ធការងារដែលធានាដល់ដំណើរការចាត់ចែងជូនជនរងគ្រោះទាក់ទងនឹងការសង្គ្រោះ ការការពារ រួមជាមួយសហគមន៍ ។

៧. ធានាប្រព័ន្ធច្បាប់៖ បញ្ចូលនូវវិធានការនានា (រដ្ឋបាល) ផ្តល់ព័ត៌មានដល់ជនរងគ្រោះ (តាមភាសាជនរងគ្រោះ) ស្តីពីសិទ្ធិ នីតិវិធីតុលាការអាជ្ញាធរពាក់ព័ន្ធ បង្កលក្ខណៈដាក់បញ្ចូលក្តីកង្វល់ដោយគិតគូរតាមដំណាក់កាលនីតិវិធីរឿងក្តីប្រឆាំងជនល្មើសដោយពុំមានព្យសនកម្មដល់សិទ្ធិការពារក្តី (ច្បាប់ ACTIP) ។

៨. តួនាទីសង្គមស៊ីវិល៖ គាំទ្រការផ្តល់ជំនួយរបស់អង្គការសង្គមស៊ីវិល ដែលជួយជនរងគ្រោះស្វែងរកសំណង សម្រួលការថែទាំ និងផ្តល់សេវាជាកិច្ចសហការជាមួយសមត្ថកិច្ច។

៩. ជំរុញការធ្វើនិងអនុម័តច្បាប់ស្តីពីការការពារកុមារជាជនរងគ្រោះ និងសាក្សី ។

១០. បង្កើត និងជំរុញការអនុវត្តបែបកុមារមេត្រីតាមបទដ្ឋានជាតិរួម ។

## គ. ការផ្តន្ទាទោស

ការចាត់ទុកជាអំពើល្មើសច្បាប់ ការផ្តន្ទាទោស ការអនុវត្តច្បាប់ និងការវិនិច្ឆ័យទោស៖

១. ការចាត់ទុកជាអំពើល្មើសច្បាប់ ៖ មានចែងក្នុងច្បាប់ប្រទេស និងច្បាប់អន្តរជាតិ ។

២. ការផ្តន្ទាទោស៖ ជំរុញ និងលើកកម្ពស់ការផ្តន្ទាទោសជនល្មើសឱ្យបានត្រឹមត្រូវតាមនីតិវិធី និងច្បាប់កំណត់ ។

៣. ពង្រឹងការអនុវត្តច្បាប់ តាមរយៈការផ្សព្វផ្សាយពង្រីកការយល់ដឹង ធ្វើការតាមដាន ស៊ើបអង្កេត ឈានទៅបង្ក្រាប កសាងសំណុំរឿង ប្រមូលភស្តុតាងដើម្បីដាក់បន្ទុកជនល្មើសតាមនីតិវិធីច្បាប់ ។

៤. ការវិនិច្ឆ័យទោស ៖ ជំរុញការផ្តន្ទាទោស ។

៦. ជំរុញការអនុវត្តទោសបន្ថែមពាក់ពន្ធ័នឹងការហាមស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើជនបរទេសដែលទទួលការកាត់ទោសពីបទល្មើសផ្លូវភេទប្រឆាំងកុមារ ។

## ឃ. ការអនុវត្តច្បាប់ ផ្តន្ទាទោស វិនិច្ឆ័យទោស

១. កសាងសមត្ថភាព ៖ ពង្រឹងសមត្ថភាពឱ្យបានខ្លាំងក្លាដល់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា ចៅក្រម មន្ត្រីអន្តោប្រវេសន៍ មន្ត្រីការបរទេស មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច មន្ត្រីក្រសួងការងារ មន្ត្រីសង្គមកិច្ច និងមន្ត្រីពាក់ព័ន្ធ ។

២. បង្កើតព្រះរាជអាជ្ញាឯកទេស៖ ចាំបាច់ដើម្បីដោះស្រាយតែរឿងក្តីជួញដូរមនុស្ស ។

៣. បង្កើតយន្តការឯកទេស ៖ ជាយន្តការឯកទេសក្នុងក្របខ័ណ្ឌជាតិ អន្តរជាតិ ។

៤. បង្កើតវិធីសាស្ត្រស៊ើបអង្កេតបុរេសកម្មតាមកាលៈទេសៈសមស្រប អនុវត្តការឃ្លាំមើលបណ្តាវិធានការបុរេសកម្មផ្សេងទៀតដើម្បីប្រមូលភស្តុតាង បើកករណីនាំដល់ការផ្តន្ទាទោស ទោះបីគ្មានសក្ខីកម្មជនរងគ្រោះក៏ដោយ ។

៥. ពិនិត្យលទ្ធភាពច្បាប់កំណត់លើកលែងការបង់ថ្លៃ ដើម្បីសម្រាលដល់ការចូលស្នាក់នៅបណ្តោះអាសន្នដល់ជនរងគ្រោះ ក្នុងគោលបំណងផ្តល់សក្ខីកម្ម ឬសហការក្នុងដំណើរការផ្តន្ទាទោស ។

៦. ការផ្តន្ទាទោសជនល្មើសគប្បីដាក់បញ្ចូលគ្រប់ទម្រង់នៃអំពើធ្វើអាជីវកម្មលើមនុស្ស ដោយអនុម័តច្បាប់ និងពង្រឹងការអនុវត្ត ។

៧. ប្រឆាំងឧក្រិដ្ឋជនឆ្លងដែន ផ្តន្ទាទោសជនល្មើសយោងតាមច្បាប់របស់ប្រទេសនីមួយៗ ។

៨. សម្របសម្រួលកិច្ចសហប្រតិបត្តិការនៅថ្នាក់ជាតិ និងអន្តរជាតិ ក្នុងរឿងក្តីអាចជាប់ទាក់ទងអំពើជួញដូរមនុស្ស ដូចជាការសំអាតប្រាក់ អំពើពុករលួយ ការតំពន្ធទេសន្តរប្រវេសន៍ និងគ្រប់ទម្រង់ឧក្រិដ្ឋកម្មដែលមានការចាត់តាំង ។

៩. រៀបចំផែនការជំនួយផ្លូវច្បាប់ ដែលអាចមានលទ្ធភាព ជំរុញការផ្តន្ទាទោសដែលអាចធ្វើទៅបានក្នុងការជួយគ្នាក្នុងដំណើរការក្តី ដើម្បីជំរុញការផ្តន្ទាទោស ដាក់ទោស (គិតទាំងសន្ធិសញ្ញាអាស៊ាន ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងកិច្ចព្រមព្រៀងទ្វេភាគីនានា) ។

១០. ចែករំលែកព័ត៌មានដើម្បីលើកទឹកចិត្ត និងជំរុញដំណើរការស៊ើបអង្កេត បង្កើតក្រុមឯកទេសប្រព្រឹត្តកម្មរួមគ្នា ពន្លឿនការស៊ើបអង្កេត ផ្តន្ទាទោសរឿងក្តីធ្ងន់ធ្ងរ ឬមានស្ថានទម្ងន់ទោស (ថ្នាក់តំបន់) ។

១១. ផ្តន្ទាទោសមន្ត្រីពុករលួយ និងមន្ត្រីជួយសម្រួលបិទបាំងអំពើជួញដូរ ដោយគ្មានការ អត់ឱន ឬលើកលែង ។

១២. យន្តការការពារ គប្បីអនុវត្តប្រកបដោយប្រសិទ្ធភាពសម្រាប់សាក្សីនៃអំពើជួញដូរ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

១៣. ការទទួលខុសត្រូវរបស់ជនល្មើសនៅក្នុងអំពើជួញដូរ ត្រូវតែធ្វើឡើងសមស្រប ទាំងនីតិបុគ្គល (ACTIP) ។

១៤. បង្កើនកិច្ចស៊ើបអង្កេត៖ ពង្រឹងបច្ចេកទេស មធ្យោបាយប្រើប្រាស់លក្ខណៈជាប្រព័ន្ធក្នុងការរឹបអូសទ្រព្យសម្បត្តិ ក្នុងបំណងដកហូតជាយថាហេតុ ធានាការដាក់ទោសសមាមាត្រទៅនឹងចរិតធ្ងន់ធ្ងរនៃបទល្មើស ។

១៥. បង្កើនការបណ្តុះបណ្តាលជំនាញដល់មន្ត្រីអនុវត្តច្បាប់លើទ្រឹស្តីនិងការអនុវត្តតាម បែបកុមារមេត្រីក្នុងដំណើរការស៊ើបអង្កេត និងផ្តន្ទាទោស ។

## ខ. កិច្ចសហប្រតិបត្តិការ សម្របសម្រួល

១. បង្កើនកិច្ចសហប្រតិបត្តិការជាតិ ប្រទេសពាក់ព័ន្ធជាអន្តរជាតិ អង្គការក្នុងស្រុក និងអន្តរជាតិ សំដៅពង្រឹងសមត្ថភាពអនុវត្តដោយប្រសិទ្ធភាព ។

២. កែលម្អការកសាងសមត្ថភាពគ្រប់ផ្នែក នេះជាសមាសភាគមួយសំខាន់ ។

៣. បង្កើនកិច្ចសហការ ដោយពង្រឹងកិច្ចប្រតិបត្តិការជាតិ អន្តរជាតិ (អាស៊ាន) ទ្វេភាគី ពហុភាគី និងបង្កើតក្រុមស៊ើបអង្កេតរួមគ្នា ។

៤. ចាត់តាំងជនបង្គោល ដើម្បីធ្វើទំនាក់ទំនង ចែករំលែកទិន្នន័យ ផ្លាស់ប្តូរព័ត៌មាន ពង្រឹងការអនុវត្តគោលនយោបាយ កម្មវិធីបង្ការទប់ស្កាត់ និងការពារជនរងគ្រោះ

- សម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ផ្នែកឯកជន ប្រព័ន្ធផ្សព្វផ្សាយ..
- បន្ត និងបង្កើនការកសាងគោលការណ៍ដឹកនាំ ផ្អែកតាមគោលការណ៍ជាតិ ទ្វេភាគី ពង្រឹងភាពជាដៃគូ...

៥. ប្រើប្រាស់កិច្ចសហប្រតិបត្តិការអន្តរជាតិ បទបញ្ញត្តិ សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងរឿងក្តីព្រហ្មទណ្ឌ (អាស៊ាន) បង្កើនទំនុកចិត្តដើម្បីធានាដល់ការស៊ើប អង្កេត និងដាក់ទោស ។

៦. ប្រើប្រាស់យន្តការអន្តរជាតិ ដូចជា Interpol សេនានុពន្ធ័នគរបាលអន្តរជាតិ និងបណ្តាទិន្នផ្ទាន Interpol ។

៧. កិច្ចសហការតំបន់អាស៊ាន រវាងក្រុមការងារទទួលបន្ទុកចំណុះឧត្តមមន្ត្រីអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងកិច្ចប្រជុំប្រធានឯកទេសនិងគិតដល់ការពាក់ព័ន្ធផ្សេងទៀត ។

៨. ពង្រឹងការកសាងសមត្ថភាព ដោយកែលម្អការរៀបចំទទួលសំណើ រៀបចំជំនួយផ្នែកច្បាប់ បត្យាប័ន អនុវត្តច្បាប់ឆ្លងដែន ។

៩. ផ្តល់ប្រយោជន៍ រួមគ្នាជាមួយដៃគូជាតិ អន្តរជាតិ តំបន់ អនុតំបន់ ក្នុងការផ្តល់បច្ចេកទេស/មូលនិធិប្រកបដោយនិរន្តរភាព ។

## ច. បន្ទអនុវត្ត និងពិនិត្យឡើងវិញ

១. ព្យាយាមរួមបញ្ចូលកម្មវិធី និងសកម្មភាពពាក់ព័ន្ធទៅក្នុងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ាន ទៅក្នុងផែនការសកម្មភាពជាតិ ដើម្បីធានាភាពជោគជ័យ ។

២. យន្តការ SOMTC ដោយមានការគាំទ្រពីក្រុមការងារទទួលបន្ទុកអំពើជួញដូរមនុស្សរបស់ SOMTC ត្រូវមើលការខុសត្រូវលើការអនុវត្តសកម្មភាពនេះ ។